ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៨ លេខ ៥៣ ត្រីមាសទី ០៣ ឆ្នាំ ២០១៨

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

០៦-០៧-២០១៨ -ព្រះរាជក្រម នស/រកម/០៧១៨/០១៣ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនស្ទេថេក ខូ អិលធីឌី ៦២៥១

### ២~ព្រះរាជក្រឹត្យ

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧០ ស្តីពី ការតែងតាំងព្រះរាជាគណៈថ្នាក់ចត្វាគណៈមហានិកាយ និងព្រះរាជាគណៈកិត្តិយសគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០៩ អង្គ ៦២៦៩

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧១ ស្តីពី ការតែងតាំង ឯកឧត្តម **ខាន់ វណ្ណៈ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ នៅក្រសួងយុត្តិធម៌ ៦២៧០

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯកដល់លោកឧត្តមសេនីយ៍ទោ **ហ៊ូ វ៉ាន់នី** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦២៧១

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧៣ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ទោ ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ០២ រូប ៦២៧២

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧៤ ស្តីពី ការដកហូតឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ត្រីពីលោក **ឡាយ ណារិទ្ធ** នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៦២៧៣

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧៥ ស្តីពី ការផ្ទេរបញ្ចូលលោក **ចាយ បូរាណ** ក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ មកជាឋានន្តរស័ក្តិ ឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ៦២៧៤

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧៦ ស្តីពី និយ័តកម្មក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដល់មន្ត្រីរាជការ ០៦ រូប នៅក្រសួងអភិវឌ្ឍន៍ជនបទ ៦២៧៥

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧៧ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការ ១០ រូប នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦២៧៧

៣០-០៦-២០១៨ -ព្រះរាជក្រឹត្យ នស/រកត/០៦១៨/៦៧៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ លោកជំទាវ និងអស់លោក ចំនួន ០២ រូប ៦២៧៩


# II_រាជរដ្ឋាភិបាល

## ១_អនុក្រឹត្យ


២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៨៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦២៨០

២៩-០៦-២០១៨ -អនុក្រឹត្យលេខ ៨៩ អនក្រ.បក ស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ៦២៨៣

២៩-០៦-២០១៨ -អនុក្រឹត្យលេខ ៩០ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ៦២៨៧

២៩-០៦-២០១៨ -អនុក្រឹត្យលេខ ៩១ អនក្រ.បក ស្តីពី ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់ ៦២៨៩

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦២៩៣

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៦២៩៤

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៥ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦៣០៣

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៦ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៣០៤

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៣០៥

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៨ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហាន ៦៣១៣

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦១៩ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៣២២

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦២០ អនក្រ.តត ស្តីពី ការផ្ទេរបញ្ចូល និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ ៦៣២៣

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦២១ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៦៣២៥

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦២២ អនក្រ.តត ស្តីពី ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦៣២៧

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦២៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៣២៨

២៧-០៦-២០១៨ -អនុក្រឹត្យលេខ ៦២៤ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៦៣២៩

## ២-សេចក្តីណែនាំ

០៦-០៧-២០១៨ -សេចក្តីណែនាំលេខ ០១ សណន ស្តីពី ការផ្អាកលក់ដូរ និងពិសាគ្រឿងស្រវឹងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ៦ ឆ្នាំ ២០១៨ ៦៣៣២

# III-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៧-០៥-២០១៨ -ប្រកាសលេខ ៤៩៥ សហវ.ប្រក ស្តីពី ការកែសម្រួលការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦៣៣៤

០៨-០៥-២០១៨ -ប្រកាសអន្តរក្រសួងលេខ ៤៩៧ សហវ.ប្រក ស្តីពី តម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងនីតិវិធីអនុវត្តចំណាយ ៦៣៤៩

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

០៣-០៤-២០១៨ -ប្រកាសលេខ ១១៩ ឧស.កឧ.ប្រក ០៤ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូ អាយ ស៊ី អីភែរីល មេនូហ្វេកឆឺរីង បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦៣៦៤

# ព្រះរាជក្រម

នស/រកម/០៧១៨/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
## ស្ដីពី
## ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឲ្យក្រុមហ៊ុន ស្ទេថេក ខូ អិលធីឌី

**មាត្រា១.-**

អនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចំពោះក្រសួងរ៉ែនិងថាមពល និងអគ្គិសនីកម្ពុជា ឲ្យក្រុមហ៊ុន ស្ទេថេក ខូ អិលធីឌី ក្នុងក្របខ័ណ្ឌកិច្ចព្រមព្រៀងអនុវត្តគម្រោង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុន ស្ទេថេក ខូ អិលធីឌី និងកិច្ចព្រមព្រៀងទិញថាមពលអគ្គិសនី រវាងអគ្គិសនីកម្ពុជា និងក្រុមហ៊ុន ស្ទេថេក ខូ អិលធីឌី ដែលបានចុះហត្ថលេខានៅរាជធានីភ្នំពេញ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ ។ ការធានានេះ មានអត្ថបទទាំងស្រុងដែលបានចុះហត្ថលេខា កាលពីថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០១៨ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរាជរដ្ឋាភិបាលកម្ពុជា ភ្ជាប់មកជាមួយនេះ ។

**មាត្រា២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តលិខិតធានាទូទាត់នេះ ។

**មាត្រា៣.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃសុក្រ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នស.រកម.០៧១៨.០០៦

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ហត្ថលេខា**
**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

លេខ:៧៣០ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃចន្ទ ១២រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សយ សុខា**

២/២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០០៦.........សហវ

ថ្ងៃច័ន្ទ ៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨

# លិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់

**ជូនចំពោះ** : **លោក ហេង សុជាតិ**
ក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី

**អាសយដ្ឋាន** : លេខ ៥៤១, ផ្លូវលេខ ១០០៣, សង្កាត់ភ្នំពេញថ្មី,
ខណ្ឌសែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

**ទូរសារ** : ៨៥៥ ២៣ ២១៥ ៤៧១

**យោង** :

(ក) លិទ្ធិប្រទាន លេខ ២៩ សប្រទ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** (លិខិតសិទ្ធិប្រទានក្នុងឧបសម្ព័ន្ធ១)។

(ខ) កិច្ចព្រមព្រៀងអនុវត្តគម្រោង (IA) ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ ដែលបានចុះហត្ថលេខារវាង រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយ **រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល (ក.រ.ថ)** និង **ក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី** (SchneiTec Co., Ltd.) (**ក្រុមហ៊ុន**)។

(គ) **អគ្គិសនីកម្ពុជា** ជាសហគ្រាសរដ្ឋ មានការទទួលខុសត្រូវមានកំណត់ បានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៦/១០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៩៦ មានការិយាល័យធំរបស់ខ្លួន តាំងនៅផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា រាប់បញ្ចូលទាំងអ្នកបន្តវេន និងអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (អ.ក) ដែលបានចុះកិច្ចព្រមព្រៀងទិញអគ្គិសនី (PPA) ជាមួយក្រុមហ៊ុន ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

(ឃ) រាជរដ្ឋាភិបាលកម្ពុជា យល់ព្រមផ្តល់ : (១)-ការធានាលើការទូទាត់ថ្លៃទិញថាមពលអគ្គិសនី ក្នុងករណីដែល អ.ក មិនធ្វើការទូទាត់ និង (២)-ការធានាលើការទូទាត់បញ្ចប់កិច្ចព្រមព្រៀង ស្របតាមប្រការ ១៥.៥ នៃ PPA និង/ឬ IA ។

(ង) តាមការតម្រូវក្នុងប្រការ ៤.៨ នៃកិច្ចព្រមព្រៀងអនុវត្តគម្រោង **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ស.ហ.វ)** ជំនួសមុខឱ្យរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា (**រាជរដ្ឋាភិបាល ឬ អ្នកធានា**) បានយល់ព្រមចុះហត្ថលេខាលើលិខិតធានាលើការទូទាត់ ដោយ អ.ក/ក.រ.ថ ស្របតាម PPA ។ ក្នុងលិខិតធានានេះ រាជរដ្ឋាភិបាល និងក្រុមហ៊ុន ត្រូវបានហៅកាត់ដោយឡែក ថា *"ភាគី"* និងហៅកាត់រួមគ្នាថា *"ភាគីទាំងពីរ"* ។

**ដូច្នេះ យើងខ្ញុំសូមធានា ថា :**

១. អ្នកធានា ដោយមានជំនឿចិត្ត និងដោយកិត្តិយស នៃរាជរដ្ឋាភិបាលកម្ពុជា សូមធានា និងសន្យា ដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធ ទូទាត់ឱ្យក្រុមហ៊ុន នូវចំនួនទឹកប្រាក់ណាមួយ និងទាំងអស់ ដែលត្រូវបង់ និងជំពាក់ដោយ ក.រ.ថ ឬ អ.ក ឱ្យក្រុមហ៊ុន ស្របតាម IA ឬ PPA ដែល ក.រ.ថ ឬ អ.ក ខកខានពុំបានទូទាត់ អនុលោមតាមអាណត្តិ នៃ IA ឬ PPA ។

២. លិខិតធានានេះ ត្រូវជាការធានាថាបន្តរហូត និងឱ្យបានសមស្រប និងត្រូវទូទាត់តុល្យការទឹកប្រាក់ ដែលត្រូវបង់ឱ្យក្រុមហ៊ុន គ្រប់ពេលដោយ ក.រ.ថ និង/ឬ អ.ក ស្របតាម IA និង/ឬ PPA ទោះជាមានលិខិតជូនដំណឹងណាមួយ ស្តីពីការបញ្ចប់កិច្ចព្រមព្រៀង ការរំលាយ ឬ អសមត្ថភាព ឬការផ្លាស់ប្តូរណាមួយ ក្នុងព្រះរាជក្រឹត្យពាក់ព័ន្ធនឹង ក.រ.ថ និង/ឬ អ.ក ឬក្នុងនាម ឬរបៀប ឬការទូទាត់គណនីណាមួយ ឬបញ្ហាផ្សេងទៀតក៏ដោយ ។

៣. មុនពេលឈានដល់ការអនុវត្តលិខិតធានានេះ និងធ្វើសំណើសុំការទូទាត់ពីអ្នកធានា ក្រុមហ៊ុន ត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរ ស្នើសុំការទូទាត់ពី ក.រ.ថ និង/ឬ អ.ក តាមជាក់ស្តែង ។ ក្រោយរយៈពេលហុកសិប (៦០) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃវិក្កយបត្រ ដូចមានចែងក្នុងប្រការ ៨.៦ នៃ PPA ឬសំណើសុំទូទាត់ណាមួយពីក្រុមហ៊ុន ទៅ អ.ក ឬ ក.រ.ថ ត្រូវបានទទួលដោយ អ.ក ឬ ក.រ.ថ ក្រុមហ៊ុនអាចជូនដំណឹងទៅអ្នកធានា ជាលាយលក្ខណ៍អក្សរថាការទូទាត់ ដោយ ក.រ.ថ និង/ឬ អ.ក បានហួសកាលកំណត់ និងលើកសំណើសុំទូទាត់ពីអ្នកធានា ស្របតាមលិខិតធានានេះ ហើយអ្នកធានា ត្រូវធ្វើការទូទាត់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ។ ការយឺតយ៉ាវក្នុងការទូទាត់របស់អ្នកធានា ក្រោមលិខិតធានានេះ ត្រូវគិតការប្រាក់តាមអត្រា

ការប្រាក់ប្រចាំឆ្នាំ LIBOR បូក ៣% (បីភាគរយ)។ ហើយពុំមានសំណើណាមួយ ដែលធ្វើឡើង ដោយក្រុមហ៊ុន ស្របតាមលិខិតធានានេះ ដែលប៉ះពាល់ ឬដកហូតសិទ្ធិ របស់ក្រុមហ៊ុន ក្នុងការធ្វើសំណើបន្ថែម ឬផ្សេងទៀត ចំពោះវិក្កយបត្រ ដែលមិនទាន់ទូទាត់ផ្សេងទៀត។

ទឹកប្រាក់ទាំងអស់ ដែលអ្នកធានាត្រូវទូទាត់តាមលិខិតធានានេះ ត្រូវបង់ទាំងអស់ចូលក្នុងគណនីធនាគារ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្រុមហ៊ុនបានកំណត់ ជាដុល្លារអាមេរិក ឱ្យក្រុមហ៊ុន។

៤. រាល់សំណើសុំទូទាត់ណាមួយ ដែលបានធ្វើឡើង តាមលិខិតធានានេះ ត្រូវធ្វើឡើងតាមរយៈអ្នករត់សំបុត្រ ឬដោយផ្ទាល់ ដោយមន្ត្រីទទួលបានការអនុញ្ញាតស្របច្បាប់ របស់ក្រុមហ៊ុន នៅការិយាល័យរបស់អ្នកធានា និងត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ ដែលមានចុះហត្ថលេខាដោយមន្ត្រី ដែលបានទទួលការអនុញ្ញាតស្របច្បាប់របស់ក្រុមហ៊ុន ដោយគ្មានកាតព្វកិច្ចណាផ្សេងទៀត ដោយបញ្ជាក់ថា :

"យើងខ្ញុំ សូមបញ្ជាក់ថា :

(១). ក្រុមហ៊ុន ស្នេថេក ខូ អិលធីឌី ឬអ្នកបន្តវេន ឬអ្នកដែលបានអនុញ្ញាតឱ្យទទួលសិទ្ធិ (ក្រុមហ៊ុន) បានធ្វើសំណើសុំទូទាត់ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អ្នកធានា) នូវចំនួនទឹកប្រាក់.......... {បញ្ចូលទឹកប្រាក់} ដុល្លារអាមេរិក ស្របតាមចំណុចទី១ នៃលិខិតធានារបស់រាជរដ្ឋាភិបាលលើការទូទាត់ ចុះថ្ងៃទី...... ខែ....... ឆ្នាំ........ រវាងអ្នកធានា និង ក្រុមហ៊ុន។

(២). ចំនួនទឹកប្រាក់ខាងលើ គឺដល់ពេលត្រូវទូទាត់ដោយ អ.ក ឬ ក.រ.ថ ស្របតាម PPA/IA រវាងក្រុមហ៊ុន និង អ.ក/ក.រ.ថ និងពុំមានផ្នែកណាមួយ នៃចំនួនទឹកប្រាក់ ដែលបានបញ្ជាក់ខាងលើ ជាកម្មវត្ថុនៃវិវាទ រវាង អ.ក/ក.រ.ថ និងក្រុមហ៊ុន ដែលមិនទាន់ដោះស្រាយដាច់ស្រេចនោះទេ។

(៣). សំណើសុំទូទាត់ពី ក.រ.ថ/អ.ក ជាលាយលក្ខណ៍អក្សរ បានផ្ញើរួចហើយ ។

(៤). ចំនួនទឹកប្រាក់នេះ នៅពុំទាន់បានទូទាត់ដោយ ក.រ.ថ/អ.ក រហូតដល់ថ្ងៃនេះ ។

៥. អ្នកធានា សូមអះអាង នៅថ្ងៃនេះថា :

- អ្នកធានា មានសិទ្ធិពេញលេញ និងការអនុញ្ញាតស្របច្បាប់ ក្នុងការទទួលកាតព្វកិច្ច ការចុះហត្ថលេខា និងការប្រគល់ ព្រមទាំងប្រតិបត្តិ និងអង្កេត តាមអាណត្តិ និងបញ្ញត្តិនានា នៃលិខិតធានានេះ ។

- លិខិតធានានេះ ជាកាតព្វកិច្ចស្របច្បាប់ មានសុពលភាព និងប្រសិទ្ធភាព និងជាឯកសារចំណងផ្លូវច្បាប់ អនុលោមតាមអាណត្តិ របស់លិខិតធានានេះ ។
- រាល់សកម្មភាពចាំបាច់ត្រូវបានអនុវត្ត និងរាល់ការយល់ព្រម ដែលតម្រូវឱ្យមាន ត្រូវបានទទួលរួចហើយ ក្រោមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សិទ្ធិក្នុងការចុះហត្ថលេខា ការប្រគល់ និងការប្រតិបត្តិ លិខិតធានានេះ ។
- កាតព្វកិច្ច និងកិច្ចព្រមព្រៀងនានា របស់អ្នកធានា ក្នុងលិខិតធានានេះ ជាកាតព្វកិច្ចដោយគ្មានលក្ខខណ្ឌរបស់អ្នកធានា ដើម្បីអនុវត្តកាតព្វកិច្ចទាំងនេះ សម្រាប់ផ្តល់ការជឿទុកចិត្ត និងកិត្តិយសរបស់អ្នកធានា ។
- អ្នកធានា បានយល់ព្រមដោយគ្មានលក្ខខណ្ឌ និងដោយគ្មានការបដិសេធថា ការចុះហត្ថលេខា ការប្រគល់ និងការអនុវត្តដោយអ្នកធានា តាមលិខិតធានានេះ គឺជាសកម្មភាពពាណិជ្ជកម្ម មិនមែនជាសកម្មភាពសាធារណៈ ឬជាសកម្មភាពរដ្ឋាភិបាលទេ ហើយលិខិតធានានេះ ជាកាតព្វកិច្ចដោយផ្ទាល់ ដោយគ្មានលក្ខខណ្ឌ និងដោយមិនអាចបដិសេធបានឡើយ ។
- ប្រសិនបើមានបណ្តឹងណាមួយ ចំពោះអ្នកធានា ឬចំពោះទ្រព្យសម្បត្តិរបស់អ្នកធានា ក្នុងយុត្តាធិការណាមួយ ដែលទាក់ទងនឹងលិខិតធានានេះ ពុំមានអភ័យឯកសិទ្ធិណាមួយពីបណ្តឹងនោះ ត្រូវបានទាមទារដោយ ឬតាងនាមរបស់ខ្លួន ឬទាក់ទងទៅនឹងទ្រព្យសម្បត្តិរបស់ខ្លួន ដែលមានបច្ចុប្បន្ន ឬអាចទទួលបាននាពេលអនាគត។

៦. លិខិតធានានេះ ត្រូវមានសុពលភាព និងប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទចូលជាធរមាន (Effective Date) នៃ PPA រហូតដល់បញ្ចប់អាណត្តិ នៃ IA ឬ PPA និងត្រូវបន្តពេលយូរតទៅទៀត តាមចំនួនទឹកប្រាក់ជំពាក់ណាមួយ ដែល ក.រ.ថ ឬ អ.ក នៅជំពាក់ក្រុមហ៊ុន ទាក់ទងនឹងអាណត្តិនោះ ឬនៅពុំទាន់ទូទាត់។ ប៉ុន្តែ ចំពោះការធានាលើថ្លៃទិញអគ្គិសនី ក្នុងករណីដែល អ.ក ពុំបានទូទាត់ លិខិតធានានេះត្រូវមានប្រសិទ្ធភាព ចាប់ពីថ្ងៃដំណើរការអាជីវកម្ម នៃគម្រោង (Commercial Operation Date) ឬចាប់ពីកាលបរិច្ឆេទដាក់ឱ្យដំណើរការសាកល្បង ដូចមាននិយមន័យ កំណត់នៅក្នុង PPA នៃគម្រោង។

៧. មិនយកការខកខាន ឬការយឺតយ៉ាវណាមួយ ដោយក្រុមហ៊ុន ក្នុងការអនុវត្តសិទ្ធិ ឬការដោះស្រាយណាមួយ ក្រោមលិខិតធានានេះ ជាការបដិសេធសិទ្ធិ ឬការដោះស្រាយឡើយ។ គ្មានការអនុវត្តសិទ្ធិ ឬការដោះស្រាយតែមួយ ឬតែមួយផ្នែក ច្រានចោលការអនុវត្តបន្ថែមនូវសិទ្ធិ

ឬការដោះស្រាយណាមួយផ្សេងទៀតឡើយ។ ការបដិសេធរបស់ក្រុមហ៊ុន មានប្រសិទ្ធភាព លុះត្រាតែការបដិសេធនោះ ធ្វើឡើងជាលាយលក្ខណ៍អក្សរ។ សិទ្ធិ និងការដោះស្រាយនានា ដែលបានផ្តល់ឱ្យក្រុមហ៊ុន ដោយលិខិតធានានេះ គឺជាការផ្តល់បន្ថែម និងមិនលើកលែងសិទ្ធិ និងការដោះស្រាយណាមួយ ដែលបានផ្តល់ដោយច្បាប់ឡើយ។

៨. រាល់លិខិតជូនដំណឹង ឬលិខិតឆ្លើយឆ្លងផ្សេងៗទៀត (ដែលត្រូវហៅកាត់រួមគ្នាថា "លិខិតជូនដំណឹង") ដែលត្រូវផ្តល់ ឬធ្វើឡើង ស្របតាមលិខិតធានានេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងត្រូវបញ្ជូនទៅបុគ្គល និងអាសយដ្ឋាន ដូចមានបញ្ជាក់ខាងក្រោម ដោយត្រូវប្រគល់ផ្ទាល់ដៃ ឬតាមប្រៃសណីយ៍។ រាល់លិខិតជូនដំណឹង ត្រូវបានចាត់ទុកថា បានប្រគល់ :

(ក). ពេលបានប្រគល់ផ្ទាល់ដៃ, ឬ

(ខ). នៅពេលប្រគល់ដោយមានការកត់ត្រាត្រឹមត្រូវ និងមានការបានទទួល ដោយអ្នកផ្ញើឯកសារអន្តរជាតិ ដែលមានការទទួលស្គាល់ បញ្ជូនទៅភាគីទទួល ទៅកាន់អាសយដ្ឋានដូចខាងក្រោម (ឬក៏អាសយដ្ឋានដទៃទៀត ដែលភាគីទទួលនោះ អាចបញ្ជាក់តាមរយៈលិខិតជូនដំណឹង ឱ្យទៅភាគីប្រគល់លិខិតតាមអាសយដ្ឋាន ឬលេខទូរសារ ចែងខាងក្រោម) :

**សម្រាប់ អ្នកធានា :**

| | | |
|---|---|---|
| ជូនចំពោះ | : | ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| អាសយដ្ឋាន | : | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ផ្លូវលេខ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារលេខ | : | ៨៥៥ ២៣ ៤២៧ ៧៩៨ |

**សម្រាប់ ក្រុមហ៊ុន :**

| | | |
|---|---|---|
| ជូនចំពោះ | : | **លោក ហេង សុជាតិ** |
| អាសយដ្ឋាន | : | ផ្ទះលេខ ៥៤១, ផ្លូវលេខ ១០០៣, សង្កាត់ភ្នំពេញថ្មី,<br>ខណ្ឌសែនសុខ, រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា |
| ទូរសារលេខ | : | ៨៥៥ ២៣ ២១៥ ៤៧១ |

ឬក៏អាសយដ្ឋានផ្សេងទៀត ដែលភាគីណាមួយ អាចជូនដំណឹងឱ្យភាគីមួយទៀត។

៩. អ្នកធានា មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីក្រុមហ៊ុនឡើយ ហើយក្រុមហ៊ុន មិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិ ឬកាតព្វកិច្ចទាំងអស់ ឬមួយផ្នែករបស់ខ្លួន ក្រោមលិខិតធានានេះ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុន ពីអ្នកធានាឡើយ លើកលែងការផ្ទេរសិទ្ធិជូនអ្នកឱ្យខ្ចីប្រាក់ ដូចមានចែងក្នុងចំណុចទី១៥ខាងក្រោម។ ថ្វីបើមានបញ្ញត្តិក្នុងវាក្យខណ្ឌមុននេះក្តី សម្រាប់គោលបំណងអភិវឌ្ឍន៍ ឬផ្តល់ហិរញ្ញប្បទានជាអចិន្ត្រៃយ៍ដល់គម្រោង ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬបង្កើតការធានាផលប្រយោជន៍ ចំពោះសិទ្ធិ និងផលប្រយោជន៍ ក្នុង និងចំពោះលិខិតធានានេះ សម្រាប់ជាប្រយោជន៍ដល់អ្នកឱ្យខ្ចីប្រាក់។ លិខិតធានានេះ ត្រូវជាចំណងផ្លូវច្បាប់ និងមានប្រសិទ្ធភាព ជាប្រយោជន៍ដល់អ្នកធានា និងក្រុមហ៊ុន ព្រមទាំងអ្នកបន្តវេន និងអ្នកទទួលសិទ្ធិស្របច្បាប់ របស់ភាគីនីមួយៗ។

១០. សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកធានា និងក្រុមហ៊ុន ក្រោម ឬអនុលោមតាមលិខិតធានានេះ និងអាណត្តិនៃលិខិតធានានេះ ត្រូវបានគ្រប់គ្រងដោយ និងបកស្រាយ តាមច្បាប់កម្ពុជា។ ប្រសិនបើពុំមានចែងក្នុងច្បាប់កម្ពុជា ច្បាប់អង់គ្លេសនឹងត្រូវជាច្បាប់គ្រប់គ្រងមជ្ឈត្តវិនិច្ឆ័យ។

១១. ប្រសិនបើមានវិវាទ ឬការខ្វែងគំនិតណាមួយកើតឡើង តាមរូបភាពណាក៏ដោយ ឬពាក់ព័ន្ធនឹងលិខិតធានានេះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ បន្ទាប់ពីភាគីមួយ បានទទួលសេចក្តីជូនដំណឹងពីភាគីមួយទៀត ស្តីពីការកើតឡើងនៃវិវាទ អ្នកធានា និងក្រុមហ៊ុន ត្រូវដោះស្រាយវិវាទនោះ តាមរយៈការពិភាក្សា ជាមិត្តភាព។ ប្រសិនបើមិនអាចដោះស្រាយបាន តាមរយៈការពិភាក្សាជាមិត្តភាពទេ ត្រូវដាក់វិវាទនោះ ទៅមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរ ដើម្បីដោះស្រាយស្របទៅតាមវិធាន នៃមជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ។ ប្រសិនបើមានភាពមិនស្របគ្នាដោយអន្លើ រវាងបញ្ញត្តិនេះ និងវិធានរបស់មជ្ឈមណ្ឌលមជ្ឈត្តវិនិច្ឆ័យអន្តរជាតិសាំងហ្គាពួរនោះ បញ្ញត្តិនេះត្រូវមានប្រសិទ្ធភាព។ សេចក្តីសម្រេច ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយគឺជាសេចក្តីសម្រេចស្ថាពរ និងមានប្រសិទ្ធភាពទៅលើអ្នកធានា និងក្រុមហ៊ុន និងអាចយកមកអនុវត្ត នៅក្នុងតុលាការកម្ពុជាណាមួយ ដែលមានយុត្តាធិការ ធ្វើឱ្យសេចក្តីសម្រេចនេះ អនុវត្តបាន។ ភាគីទាំងពីរ ត្រូវទទួលយក និងអនុវត្តសេចក្តីសម្រេចនោះ ហើយភាគីនីមួយៗ ត្រូវទម្លាក់ចោលដោយឥតលក្ខខណ្ឌ នូវសិទ្ធិណាមួយ ដែលគេអាចមានដើម្បីតវ៉ា អំពីសុពលភាពនៃសេចក្តីសម្រេចនេះ ឬយុត្តាធិការនៃតុលាការមជ្ឈត្តវិនិច្ឆ័យនោះ ដើម្បីធ្វើសច្ចការឯកសារយោងណាមួយ ទៅមជ្ឈត្តវិនិច្ឆ័យ ដែលលិខិតធានានេះ មាន

ប្រសិទ្ធភាពអនុវត្ត។ ការទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវធ្វើជាប្រាក់ដុល្លារអាមេរិក។ ចំណាយលើមជ្ឈត្តវិនិច្ឆ័យ ត្រូវទូទាត់ដោយភាគីដែលចាញ់ក្តី លើកលែងតែមានការកំណត់ផ្សេងពីនេះ ដោយតុលាការមជ្ឈត្តវិនិច្ឆ័យនោះ។ ភាគីដែលទទួលខុសត្រូវទូទាត់តាមសេចក្តីសម្រេចរបស់មជ្ឈត្តវិនិច្ឆ័យ ត្រូវបង់ការប្រាក់តាមអត្រា LIBOR បូក ៣% (បីភាគរយ) ទៅឱ្យភាគីម្ខាងទៀត នៅពេលទទួលសេចក្តីសម្រេចពីមជ្ឈត្តវិនិច្ឆ័យនោះ ដោយគិតចាប់ពីកាលបរិច្ឆេទត្រូវទូទាត់ រហូតដល់ថ្ងៃទូទាត់រួច។

១២. ពាក្យសរសេរជាអក្សរធំ ដែលបានប្រើ ប៉ុន្តែពុំមានកំណត់ន័យក្នុងលិខិតធានានេះ ត្រូវមានន័យដូចបានកំណត់ក្នុង PPA ឬ IA តាមដែលអាចអនុវត្តបាន។

១៣. ប្រសិនបើបញ្ញត្តិណាមួយ ឬច្រើន ដែលមានក្នុងលិខិតធានានេះ ត្រូវបានរកឃើញថា គ្មានសុពលភាព ខុសច្បាប់ ឬគ្មានតម្លៃតាមផ្លូវច្បាប់ បញ្ញត្តិទាំងនោះ ត្រូវរក្សាតម្លៃ ដែលអនុញ្ញាតដោយច្បាប់ ហើយភាពគ្មានសុពលភាព ភាពខុសច្បាប់ ឬភាពគ្មានតម្លៃតាមផ្លូវច្បាប់នោះពុំមានឥទ្ធិពលដល់សុពលភាព នៃបញ្ញត្តិផ្សេងទៀត នៃលិខិតធានានេះឡើយ។ តាមការឯកភាពគ្នាទៅវិញទៅមក គ្មានការទូទាត់កាត់កង ការប្តឹងទាមទារទៅវិញទៅមក ការបន្ធូរបន្ថយ ឬការបន្ថយកាតព្វកិច្ចណាមួយ ដែលអ្នកធានាមាន ឬអាចមានចំពោះក្រុមហ៊ុន ត្រូវតែមានសម្រាប់អ្នកធានាចំពោះក្រុមហ៊ុន ទាក់ទងនឹងកាតព្វកិច្ចណាមួយរបស់អ្នកធានា ចំពោះក្រុមហ៊ុនក្រោមលិខិតធានានេះឡើយ។

១៤. យោងតាមចំណុចទី៦ខាងលើ លិខិតធានានេះ ត្រូវផុតកំណត់នៅពេលបញ្ចប់ IA និង PPA និងការបំពេញចប់សព្វគ្រប់នូវបទប្បញ្ញត្តិនានា តាមអាណត្តិរបស់លិខិតធានានេះ ប្រសិនបើគ្មានការតវ៉ា ហើយនៅរក្សាការធានានេះដដែល ហេតុដូចនេះ ការស្នើសុំជាលាយលក្ខណ៍អក្សរណាមួយពីក្រុមហ៊ុន ជូនមកអ្នកធានា ត្រូវតែទទួលបានក្នុងរយៈពេលមួយរយប៉ែតសិប (១៨០) ថ្ងៃក្រោយពីបានបញ្ចប់ចុងក្រោយ នៃ IA និង PPA និងការបញ្ចប់នៃមជ្ឈត្តវិនិច្ឆ័យដែលពាក់ព័ន្ធ។

១៥. ក្រុមហ៊ុនអាចប្រគល់សិទ្ធិ ឬផ្តល់ការធានាលើសិទ្ធិ ក្រោមលិខិតធានានេះ ឱ្យដល់អ្នកឱ្យខ្ចីប្រាក់។ តាមសំណើជាលាយលក្ខណ៍អក្សររបស់ក្រុមហ៊ុន យើងខ្ញុំនឹងចុះកិច្ចព្រមព្រៀងផ្ទាល់ (Direct Agreement) ដូចមានទម្រង់កំណត់នៅក្នុង IA (ដោយជំនួស "ក.រ.ថ" ដោយ "ស.ហ.វ") (ឬការទទួលស្គាល់ផ្សេងទៀត លើផលប្រយោជន៍នៃអ្នកឱ្យខ្ចីប្រាក់ តាមសំណើសមហេតុសមផល

និងមានប្រសិទ្ធភាពដូចគ្នា) ជាកម្មវត្ថុ នៃការទទួលដោយអ្នកធានា នូវឯកសារដែលរៀបចំត្រឹមត្រូវ និងចុះហត្ថលេខាដោយក្រុមហ៊ុន និងអ្នកឱ្យខ្ចីប្រាក់ ឬភ្នាក់ងាររបស់ពួកគេ។

១៦. លិខិតធានានេះ នឹងចូលជាធរមាន និងមានប្រសិទ្ធភាពអនុវត្តទៅបាន បន្ទាប់ពីទទួលបានការអនុម័ត ពីស្ថាប័ននីតិប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការរាប់អាន ពីខ្ញុំ

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**ចម្លងជូន:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងរ៉ែ និង ថាមពល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

№ 002 MEF/..............

Phnom Penh, 04 June, 2018

# GOVERNMENTAL GUARANTEE OF PAYMENTS

**MR. HENG SOCHEAT**
**SchneiTec Co., Ltd.**
Address: No. 541, Street 1003, Sangkat Phnom Penh Thmei,
Khan Sen Sok, Phnom Penh, Kingdom of Cambodia.
Fax no.: 855 23 215 471.

Dear Sir,

We refer to:

(A) Delegation of Full Power No. 29 DFP dated 31 May 2018 by Samdech Akka Moha Sena Padei Techo HUN SEN, Prime Minister of the Kingdom of Cambodia. **(please see attachment 1)**.

(B) The Implementation Agreement (“**IA**”) dated 31 May 2018, entered between the Royal Government of Cambodia (“**RGC**”) represented by Minister of Ministry of Mines, and Energy ("**MME**") and **SCHNEITEC CO., LTD.** and any of its permitted successors in title and assigns (the “**Company**”).

(C) ELECTRICITÉ DU CAMBODGE, a wholly state-owned limited enterprise incorporated by Royal Decree No. CHS/RD/0396/10 of the RGC dated 9 March 1996, with its principal office located at Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, the Kingdom of Cambodia, including its successors and permitted assignees (“**EDC**”) has entered into a Power Purchase Agreement (“**PPA**”) with the Company dated 31 May 2018.

(D) The Royal Government of Cambodia agrees to provide: (i) guarantee on power purchase in the event of non-payment by EDC; and (ii) guarantee on the payment on the termination in accordance with Section 15.5 of PPA and/or the IA.



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

(E) It is a requirement of the Implementation Agreement in accordance with Section 4.8 that the Minister of Economy and Finance ("**MEF**") on behalf of the Royal Government of Kingdom of Cambodia (the "**RGC**" or "**Guarantor**") has agreed to enter into this Guarantee of the payment obligations of EDC/MME under the PPA. In this Guarantee, the RGC and the Company are referred to individually as a "**Party**" and collectively as the "**Parties**".

**We hereby guarantee that:**

1. The Guarantor with the full faith and credit of the Royal Government of Cambodia hereby irrevocably and unconditionally guarantees and promises to pay to the Company any and every sum of money which is due and owed by MME or EDC to the Company under the IA or PPA that MME or EDC has failed to pay in accordance with the terms of the IA or PPA.

2. This Guarantee shall be a continuing security and accordingly, shall extend to cover the balance due to the Company at any time from MME and/or EDC under the IA and/or PPA, notwithstanding any notice of termination or the liquidation or other incapacity or any change in Royal Decree concerning MME and/or EDC or in the name or style thereof or any settlement of account or other matter whatsoever.

3. Before taking steps to enforce this Guarantee and demand payment from the Guarantor, the Company shall be obliged only to make demand in writing for payment from MME and/or EDC, as applicable.

   At any time after sixty (60) Days from the date of the invoice(s) as specified in Section 8.6 of the PPA or any payment demand from the Company to EDC or MME being received by EDC or MME, the Company may notify the Guarantor in writing that payment from MME and/or EDC is overdue and make a demand for payment from the Guarantor under this Guarantee, and the Guarantor shall make payment within 30 (thirty) Days of such notice. The Guarantor's late payment hereunder shall bear interest at an annual rate of LIBOR plus 3% (three percent). No demand made by the Company hereunder shall prejudice or restrict the right of the Company to make further or other demands against any other unpaid invoice(s).

   All sums payable by the Guarantor under this Guarantee shall be fully paid to the bank account designated by the Company in the Kingdom of Cambodia in US Dollars to the Company.

4. Any demand for payment made pursuant to this Guarantee shall be made by courier or in person by a duly authorized officer of the Company at the Guarantor's offices and shall be accompanied by a certificate signed by a duly authorized officer of the Company stating, without the obligation to substantiate, that:

   "We hereby certify that:

(1) SCHNEITEC CO., LTD. or a permitted successor or assign (the Company) is making this demand on the Ministry of Economy and Finance (the "Guarantor") in the amount of US Dollars .......................... [insert amount] in accordance with Section 1 of the Guarantee dated ................, between the Guarantor and the Company;

(2) The amount specified above is due and payable by EDC or MME under the PPA/IA between the Company and EDC/MME and no part of the amount specified above is the subject of a dispute between the EDC/MME and the Company that has not been adjudicated;

(3) Demand in writing for payment from MME/EDC has been made;

(4) Such amount, on the date hereof remains unpaid by MME/EDC."

5. The Guarantor warrants that, as of the date hereof:

- The Guarantor has full power, authority, and legal right to incur the obligation, to execute and deliver, and to perform and observe the terms and provisions of this Guarantee.

- This Guarantee constitutes legal, valid, binding, and enforceable obligations of the Guarantor in accordance with its terms.

- All necessary action has been taken, and all approvals required have obtained, under the Laws of the Kingdom of Cambodia to authorize the execution, delivery, and performance of this Guarantee.

- The obligations and covenants of the Guarantor in this Guarantee constitute unconditional obligations of the Guarantor, for the performance of which the full faith and credit of the Guarantor is pledged.

- The Guarantor unconditionally and irrevocably agrees that the execution, delivery, and performance by it of this Guarantee constitute commercial acts rather than public or governmental acts and such Guarantee constitutes our unconditional and irrevocable direct obligation.

- Should any proceedings be brought against it or its assets in any jurisdiction in relation to this Guarantee, no immunity from such proceedings shall be claimed by or on its behalf or with respect to its assets which it now has or may acquire in the future.

6. This Guarantee shall remain in full force and effect from the Effective Date of the PPA until the termination of the term of the IA or PPA and for so long thereafter as any amount owed to the Company by MME or EDC in connection with such term is or may be outstanding. However, such Guarantee on power purchase in the event of non-

payment by EDC shall be applicable from the Commercial Operation Date (COD) or commencement of Provisional Operation, as definition stipulated in the PPA of the Project.

7. No failure or delay by the Company to exercise any right or remedy under this Guarantee shall constitute a waiver of that right or remedy. No single or partial exercise of any right or remedy shall preclude any other or further exercise thereof or the exercise of any other right or remedy. No waiver by the Company shall be effective unless it is in writing. The rights and remedies of the Company provided by this Guarantee are cumulative and not exclusive of any rights or remedies provided by law.

8. All notices or other communications (together "Notices") to be given or made hereunder shall be in writing, shall be addressed for the attention of the person indicated below and shall be delivered personally or by courier. All Notices shall be deemed delivered:

(a) when presented personally, or

(b) upon the delivery of duly recorded and receipted delivery by a recognized international document courier, addressed to the receiving Party, at the address indicated below (or such other address as such Party may have specified by notice delivered to the delivering Party at its address or facsimile number specified below).

The address for service of Notice shall be:

For the Guarantor:

| | | |
|---|---|---|
| Attention | : | H.E. Minister, Ministry of Economy and Finance |
| Address | : | Ministry of Economy and Finance<br>Street No.92, Sangkat Wat Phnom,<br>Khan Daun Penh, Phnom Penh,<br>Kingdom of Cambodia |
| Facsimile | : | 855 23 427 798 |

For the Company:

| | | |
|---|---|---|
| Attention | : | Mr. Heng Socheat |
| Address | : | No. 541, Street 1003, Sangkat Phnom Penh Thmei,<br>Khan Sen Sok, Phnom Penh, Kingdom of Cambodia. |
| Fax No. | : | 855 23 215 471. |

or such other addresses as either Party may have notified to the other Party.

9. The Guarantor shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Company, and the Company shall not assign or transfer all or any part of its rights or obligations hereunder without the prior written consent of the Guarantor, except for transfers to Lenders as provided in paragraph 15 below. Notwithstanding the provision of the immediately preceding

sentence, for the purpose of development or permanent financing of the Project, the Company may assign or create a security interest over its rights and interests in and to this Guarantee in favor of the Lenders. This Guarantee shall be binding upon and inure to the benefit of the Guarantor and the Company and the respective successors and permitted assignees of each Party.

10. The rights and obligations of the Guarantor and the Company under or pursuant to this Guarantee and the terms of this Guarantee shall be governed by and construed according to the laws of Cambodia. If there is no applicable written law in Cambodia, the English Law shall be the law governing any arbitration.

11. If there is any dispute or difference of any kind whatsoever arising out of or in connection with this Guarantee, the Guarantor and the Company shall attempt for a period of thirty (30) days after the receipt by one Party of a notice from the other Party of the existence of the dispute to settle such dispute through mutual amicable discussions. If such dispute cannot be resolved through mutual amicable discussions, then it shall be submitted to the Singapore International Arbitration Center for arbitration in accordance with the arbitration rules of the Singapore International Arbitration Center. And if there are discrepancies between this clause and the rules of the Singapore International Arbitration Center, this clause shall govern. The award rendered shall be in writing and shall be final, conclusive and binding upon the Guarantor and the Company and award thereon may be entered in any Cambodian court having jurisdiction for its enforcement. Such Parties shall execute and perform the award and each Party hereby irrevocably waives any right it may have to contest the validity of such award or the jurisdiction of the arbitration tribunal to hear any reference to arbitration to which this Guarantee applies. Any payment under arbitration award shall be payable in U.S. Dollars. The costs of arbitration shall be borne by the losing Party, unless otherwise determined by the arbitration tribunal. The Party that is responsible to pay an arbitration award shall pay interest at a rate of LIBOR plus 3% (three percent) to the other Party in receipt of such arbitration award from the due date for the payment of such award until the date of payment of such award.

12. The capitalized terms used but not defined in this Guarantee shall have the meanings given to them in the Power Purchase Agreement or IA, as applicable.

13. If one or more provisions contained in this Guarantee is held or found to be invalid, illegal, or unenforceable in any respect, the provision(s) shall be given effect to the extent permitted by law and the invalidity, illegality, or unenforceability of any provision shall not affect the validity of the remaining provisions of this Guarantee.
Subject to mutual agreement to the contrary, no set-off counterclaim, reduction, or diminution of any obligation that the Guarantor has or may have against the Company shall be available to the Guarantor against the Company in connection with any obligation of the Guarantor to the Company under this Guarantee.

14. Subject to Clause 6 hereof, this Guarantee shall expire upon the complete termination of the IA and PPA, and fullfilment of any operative surviving provisions per the terms

thereof, and provided that, no claim has been made and remains outstanding hereunder and provided further that any written demand made to us by you hereunder must be received by us within one hundred eighty (180) days after the final termination of the IA and the PPA and completion of any related arbitration.

15. The Company is entitled to assign or grant security over its rights under this Guarantee to Lenders. We shall, at the written request of the Company, execute a Direct Agreement in substantially the form set out in the IA (substituting "MEF" for the "MME") (or such other acknoledgement of the interests of the Lenders as they may reasonably request and is substantially to the same effect), SUBJECT ONLY to receipt by it of an engrossment of such document duly excuted by the Company and the Lenders or their agent.

16. This Guarentee shall become in full and effective on its ratification by legislatures of the Kingdom of Cambodia.

Yours sincerely,

**Dr. AUN PORNMONIROTH**
Senior Minister, Minister,
Ministry of Economy and Finance

CC:
- Ministry of Royal Palace
- Secretariat of Senate
- Secretariat of National Assembly
- Council for the Development of Cambodia (CDC)
- Office of Council of Ministers
- Ministry of Foreign Affairs and International Cooperations
- Ministry of Mines, and Energy
- Cabinet of Semdech Akka Moha Sena Padei Techo HUN SEN, Prime Minister of Kingdom of Cambodia
- Electricity Authority of Cambodia
- Electricite du Cambodge (EDC)
- File

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ** : ៦៧៩ សបប

ថ្ងៃព្រហស្បតិ៍ ១រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៨

## សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម លេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣
- បានឃើញព្រះរាជក្រម លេខ នស/រកម/១០០៧/០២៧ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសម្បទាន
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៨
- បានឃើញអនុក្រឹត្យ លេខ ១១១ អនក្រ.បក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមការសម្រេច របស់គណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាល

ប្រគល់សិទ្ធិពេញសមត្ថភាព ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីចុះហត្ថលេខាលើកិច្ចព្រមព្រៀងអនុវត្តគម្រោង ជាមួយក្រុមហ៊ុន ស្មេថេក ខូ អិលធីឌី និងលើលិខិតធានាទូទាត់ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដោយអគ្គិសនីកម្ពុជា និង/ឬ ក្រសួងរ៉ែនិងថាមពល ទៅឱ្យក្រុមហ៊ុន ស្មេថេក ខូ អិលធីឌី សម្រាប់គម្រោងស្ថានីយផលិតអគ្គិសនី ដើរដោយពន្លឺព្រះអាទិត្យ កម្លាំង ៦០ មេហ្គាវ៉ាត់ នៅខេត្តកំពង់ស្ពឺ។

ក្នុងករណីដែលឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** មានធុរៈជាយថាហេតុ ឯកឧត្តមអាចផ្ទេរសិទ្ធិនេះបាន។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដោយមានសិទ្ធិពេញលេញតាមអំណាចច្បាប់ បានចុះហត្ថលេខាខាងក្រោមលើសិទ្ធិប្រទាននេះ។

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

ព្រះរាជាណាចក្រកម្ពុជា

*Kingdom of Cambodia*

ជាតិ សាសនា ព្រះមហាក្សត្រ

*Nation Religion King*

រាជរដ្ឋាភិបាល

*Royal Government*

N. 29 DFP

Phnom Penh, 31 May , 2018

DELEGATION OF FULL POWERS

- Seen the Constitution of the Kingdom of Cambodia
- Seen the Royal Decree NS/RKT/0913/903 dated 24 of September 2013 on the nomination of the Royal Government of the Kingdom of Cambodia
- Seen the Royal Kram 02/NS/94 dated 20 of July 1994 promulgating the Law on the Organization and Functioning of the Council of Ministers
- Seen the Royal Kram NS/RKM/0196/18 dated 24 of January 1996 promulgating the Law on the Establishment of the Ministry of Economy and Finance
- Seen the Royal Kram 03/NS/94 dated 05 0f August 1994 promulgating the Law on Investment of Kingdom of Cambodia and the Law on Amendment of Law on Investment of Kingdom of Cambodia promulgated by the Royal Kram NS/RKM/0303/009 dated 24 of March 2003
- Seen the Royal Kram NS/RKM/1007/027 dated 19 0f October 2007 promulgating the Law on Concessions
- Seen the Royal Kram NS/RKM/1217/019 dated 9 of December 2017 promulgating the Law on Finance for Management of the Year 2018
- Seen Sub-decree 111 អនក្រ.បក dated 27 of September 2005 on Implementation of the Law on Amendment of Law on Investment of Kingdom of Cambodia
- Referring to the decision of Council of Ministers in its plenary session on 25 May 2018

THE ROYAL GOVERNMENT

Delegates herewith to H.E. Dr. AUN PORNMONIROTH, Senior Minister, Minister of Economy and Finance, full power to sign the Implementation Agreement, and the Governmental Guarantee of Payment by the EDC/MME to SchneiTec Co., Ltd. for the Development of 60 MW Solar Photovoltaic Power Plant in Kampong Speu Province.

These powers include the powers of delegation.

In witness whereof the undersigned, the Prime Minister of the Kingdom of Cambodia with full powers duly entrusted to him, has signed this delegation of full powers.

Prime Minister

Samdech Akka Moha Sena Padei Techo HUN SEN

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពោហតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងព្រះរាជាគណៈថ្នាក់ចត្វាគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ០១អង្គ :

| | | | |
|---|---|---|---|
| ព្រះវិន័យចរិយា | **ហួរ សារិទ្ធិ** | ឡើងទីជា **ព្រះបវរសេដ្ឋា** | ព្រះរាជាគណៈថ្នាក់ចត្វា |

**មាត្រា ២**: តែងតាំងព្រះរាជាគណៈកិត្តិយសគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា ០៨អង្គ :

| | | | |
|---|---|---|---|
| ១.ព្រះគ្រូវជិរប្បញ្ញោ | **គង់ សុខ** | ឡើងទីជា **ព្រះមុនីត្រិញ្ញាណា** | ព្រះរាជាគណៈកិត្តិយស |
| ២.ព្រះគ្រូសីរីបញ្ញា | **ហ៊ីម គង់** | ឡើងទីជា **ព្រះទេពសោភ័ណ** | ព្រះរាជាគណៈ កិត្តិយស |
| ៣.ព្រះគ្រូសង្ឃបាលមុនី | **ខាន់ សារឿន** | ឡើងទីជា **ព្រះវិន័យចរិយា** | ព្រះរាជាគណៈ កិត្តិយស |
| ៤.ព្រះគ្រូវរបញ្ញា | **ម៉ី សុខាន់** | ឡើងទីជា **ព្រះអាយុវឌ្ឍនត្ថេរ** | ព្រះរាជាគណៈ កិត្តិយស |
| ៥.ព្រះភិក្ខុវិនយធីរោ | **ជឹម ម៉ុន** | ឡើងទីជា **ព្រះសីលមង្គល** | ព្រះរាជាគណៈ កិត្តិយស |
| ៦.ព្រះភិក្ខុវីរិយធម្មោ | **ម៉ន ឿន** | ឡើងទីជា **ព្រះរតនសោភ័ណ** | ព្រះរាជាគណៈ កិត្តិយស |
| ៧.ព្រះភិក្ខុបញ្ញាតេជត្ថេរ | **ស៊ា ម៉ុនណារ៉ាត** | ឡើងទីជា **ព្រះវិន័យវឌ្ឍនា** | ព្រះរាជាគណៈ កិត្តិយស |
| ៨.ព្រះភិក្ខុសច្ចបាលោ | **នួន កុសល** | ឡើងទីជា **ព្រះឥន្ទត្ថេរ** | ព្រះរាជាគណៈ កិត្តិយស |

**មាត្រា ៣** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៨*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៧០៦. ៦៥២

លេខ: ៧០០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង ឯកឧត្តម **ខាន់ វណ្ណះ** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ នៅក្រសួងយុត្តិធម៌។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៦៩២ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុយ សុខា**

៣៧៧. ១៩០៦. ៦៩៣

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** ៖ តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់លោកឧត្តមសេនីយ៍ទោ **ហ៊ឹ ម៉ាន់នី** អត្តលេខ ០១៧០០ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

កាល.១៩០៦.៦៧៥

លេខៈ៦៩៣ ស.ណ
**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** ៖ តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ទោ** ដល់នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ០២រូប ៖

១- ឧត្តមសេនីយ៍ត្រី **សួស សុខដារ៉ា** អត្តលេខ ០៣៣១២
២- ឧត្តមសេនីយ៍ត្រី **ស៊ឹម សំអេត** អត្តលេខ ១២២០៩ ។

**មាត្រា ២** ៖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧. ១៩០៦. ៦៩៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨*

លេខៈ ៦៩៤ ស.ណ
**សំណៅចម្លងដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/ ៦៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : ត្រូវបានដកហូតឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ពីលោក **ឡាយ ណារិទ្ធ** អត្តលេខ ៥៤៤១០ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ៦៩៥ ស.ណ

៣៧.១៩០៦.៦៥៦

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៨*

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីពន្ធនាគារ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៣/៨៩២ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្ទេរបញ្ចូល លោក **ចាយ បូរាណ** ពីឋាននន្តរស័ក្តិឧត្តមសេនីយ៍ត្រី ក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ មកជាឋាននន្តរស័ក្តិ ឧត្តមអគ្គានុរក្ស ថ្នាក់លេខ ៣ អត្តលេខ ៣១៣៩ នៃក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ។

**មាត្រា ២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ៕

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៩០៦.៦៩៧

លេខៈ៦៩៩ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៨*

ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពី គោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** និយ័តកម្ម ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដល់មន្ត្រីរាជការ ០៤ រូប ទៅក្នុងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ ៖

| | | | |
|---|---|---|---|
| ១- | លោក **ឡេង វ៉ាន់នីន** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ២ | មកជាវរមន្ត្រី ថ្នាក់លេខ ៤ |
| ២- | លោក **រិន ឈាង** | ពីក្រមការដើមខ្សែ ថ្នាក់លេខ ៣ | មកជាអនុមន្ត្រី ថ្នាក់លេខ ២ |
| ៣- | លោកស្រី **កែវ ពេជ្ជតា** | ពីក្រមការ ថ្នាក់លេខ ៤ | មកជាអនុមន្ត្រី ថ្នាក់លេខ ៤ |
| ៤- | លោកស្រី **សុខ សាម៉ុន** | ពីក្រមការ ថ្នាក់លេខ ៣ | មកជាអនុមន្ត្រី ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២ :** និយ័តកម្មតម្លើងថ្នាក់ ដល់មន្ត្រីរាជការ ០២ រូប ក្នុងឋានន្តរស័ក្តិ ឧត្តមមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងអភិវឌ្ឍន៍ជនបទ ៖

| | | | |
|---|---|---|---|
| ១- | លោក **គួច សេដ្ឋា** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជាថ្នាក់លេខ ១ |
| ២- | ឯកឧត្តម **សាន ចិសាល** | ពីឧត្តមមន្ត្រី ថ្នាក់លេខ ៥ | មកជាថ្នាក់លេខ ៣ |

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.១៩០៦.៦៥៥

លេខៈ ៧០១ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៨*

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តាំងស៊ប់ក្នុងក្របខ័ណ្ឌដល់មន្ត្រីរាជការ ១០ រូប ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៨ ៖

| | | |
|---|---|---|
| ១- លោកស្រី **ទិត្យ រតនៈ** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ២- លោក **ឌី សក្តិដែន** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៣- លោក **ស៊ុន លី** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៤- លោកស្រី **ខេង គីមសេង** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៥- លោកស្រី **ជាម សាងសុគន្ធា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |
| ៦- លោកស្រី **តាន់ ប៊ុនម៉ូនីកា** | មន្ត្រីបច្ចេកទេសជាន់ខ្ពស់ | ថ្នាក់លេខ ៤ |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

៧- លោកស្រី **ទួន ចណ្ណា** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

៨- លោកស្រី **ហ៊ាន ដាវី** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

៩- លោក **ផល និច្ចជាវិទ្ធ** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

១០- លោក **ឃុន ពុទ្ធរស្មី** មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*៣៣៧.១៤០៦.៦៤៩*

លេខៈ ៧០៣ ស.ណ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៨*

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៦១៨/៦៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

**គ្រឿងឥស្សរិយយស ជាតូបការ**

ចំពោះ

១- លោកជំទាវ **នាង ច័ន្ទថាណា**

២- លោក **ហ៊ាន គីមសឿន**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧. ១៨០៦.៦៩០

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៨

លេខៈ ៦៩៨ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ
ថ្ងៃអង្គារ ៦រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ..៤៨..អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៧/០១៩ ចុះថ្ងៃ សៅរ៍ ០៦រោច ខែ មិគសិរ ឆ្នាំ រកា ព.ស.២៥៦១ ត្រូវនឹងថ្ងៃទី ០៩ ខែ ធ្នូ គ.ស.២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៧ អនក្រ.បក ចុះថ្ងៃ ចន្ទ ០៨ កើត ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៧ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.**_

ត្រូវបានអនុញ្ញាតឱ្យធ្វើនិយ័តកម្មឥណទានថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ជូនអាជ្ញាធរអប្សរា, អាជ្ញាធរជាតិព្រះវិហារ, សាលាខេត្តសៀមរាប, ក្រសួងទេសចរណ៍, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, និងអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ ដូចមានបញ្ជាក់ក្នុងតារាងខាងក្រោម÷

ឯកតា÷ ពាន់រៀល

| ជំពូក | បរិយាយ | ច្បាប់ហិរ. ឆ្នាំ ២០១៨ | ឥណទាន មុន និយ័តកម្ម | និយ័តកម្ម | | ឥណទានថ្មី ក្រោយ និយ័តកម្ម |
|---|---|---|---|---|---|---|
| | | | | កើន | ថយ | |
| | **និយ័តកម្មចេញ** | | | | **49.616.000** | |
| | **៩៩-ចំណាយមិនទាន់បែងចែកមានមុខសញ្ញា** | | | | **49.616.000** | |
| 69 | ចំណាយមិនបានគ្រោងទុក | 676.504.000 | 597.310.000 | - | 49.616.000 | 547.694.000 |
| | **និយ័តកម្មចូល** | | | **49.616.000** | | |
| | **០៧.១-ក្រសួងមហាផ្ទៃ-សន្តិសុខសាធារណៈ (អគ្គស្នងការនគរបាលជាតិ)** | | | **1.230.200** | | |
| 62 | អត្ថប្រយោជន៍សង្គម (អង្គភាពនគរបាលទេសចរណ៍) | 11.116.000 | 11.116.000 | 1.230.200 | - | 12.346.200 |
| | **១០-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | **5.300.000** | | |
| 65 | ឧបត្ថម្ភធន (សាលាខេត្តសៀមរាប) | 36.175.000 | 774.045.000 | 5.300.000 | - | 779.345.000 |
| | **១៨-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** | | | **40.645.800** | | |
| 62 | អត្ថប្រយោជន៍សង្គម | 3.138.000 | 3.138.000 | 2.260.000 | - | 5.398.000 |
| 65 | ឧបត្ថម្ភធន | 100.467.300 | 100.467.300 | 38.385.800 | - | 138.853.100 |
| | -អាជ្ញាធរអប្សរា | | | 32.746.800 | | |
| | -អាជ្ញាធរជាតិព្រះវិហារ | | | 5.639.000 | | |
| | **២៧-ក្រសួងទេសចរណ៍** | | | **2.440.000** | | |
| 62 | អត្ថប្រយោជន៍សង្គម | 2.035.000 | 2.035.000 | 2.440.000 | - | 4.475.000 |

**មាត្រា២.**_

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៥ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៨៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម ទៅជា វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម សរសេរជាអក្សរកាត់ថា **វ.ព.ក.ច.** និងជាភាសាអង់គ្លេសថា **Polytechnic Institute of Kampong Cham Province** សរសេរជាអក្សរកាត់ថា **P.I.K.P.**។

**មាត្រា២ .-**

**វ.ព.ក.ច.** ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**វ.ព.ក.ច.** មានទីតាំងស្ថិតនៅភូមិទី៧ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា៣ .-**

**វ.ព.ក.ច.** មានតួនាទីជាសេនាធិការឲ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ចដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំនិងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រី និងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- កៀរគរធនធានពីប្រភពផ្សេងៗទៀតសម្រាប់ការបណ្តុះបណ្តាលនិងការសិក្សាស្រាវជ្រាវ
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឲ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា៤ .-**

**វ.ព.ក.ច.** ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិលើកម្រិតជំនាញដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត(សម្រាប់មួយកម្រិត)
- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេស សញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៥ .-**

**វ.ព.ក.ច.** ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួនតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**វ.ព.ក.ច.** មានដេប៉ាតឺម៉ង់និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះ **វ.ព.ក.ច.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .-**

**វ.ព.ក.ច.** មានក្រុមប្រឹក្សាបច្ចេកទេសមួយដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ **វ.ព.ក.ច.**។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧ .-**

**វ.ព.ក.ច.** អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនសម្រាប់ជួយបំពេញការងារ។

**មាត្រា៨ .-**

**វ.ព.ក.ច.** មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .-**

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬសញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រ ឬសញ្ញាបត្រនេះត្រូវផ្តល់ឲ្យដោយ **វ.ព.ក.ច.** និងត្រូវទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១០ .-**

ការចំណាយសម្រាប់ដំណើរការរបស់ **វ.ព.ក.ច.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិ ក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**វ.ព.ក.ច.** មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការងាររបស់ខ្លួន។

**មាត្រា១១ .-**

មន្ត្រីរាជការដែលបាន និងកំពុងបំពេញការងារនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ចាម ត្រូវផ្ទេរទៅបម្រើការងារនៅ **វ.ព.ក.ច.** ដោយរក្សាទុកតួនាទីដដែលរហូតដល់មានការតែងតាំងសារជាថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៤

## អវសានបញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

ថ្ងៃ សុក្រ ២ កោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តកំពង់ចាម
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ប្តូរចំណាត់ថ្នាក់ ពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រែប្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- លិខិតលេខ ១៣១៨ សជណ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៣៧១ សជណ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤៤១ សជណ.ពហ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១០១៩/២០១៧ ស.ណ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងការពារជាតិ
- លិខិតលេខ ៣០៦ លស ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- លិខិតលេខ ១០២ ស.អ.យ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៨ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## សម្រេច

**មាត្រា ១.-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងដូចខាងក្រោម÷

-ទីតាំងដីចំនួនពីរកន្លែង របស់អង្គភាពចំណុះតំបន់ប្រតិបត្តិការសឹករង ខេត្តកំពត មានទំហំ ៥០ ១៥០ ម៉ែត្រក្រឡា ស្ថិតនៅភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត។

-ទីតាំងដី និងអគារប៉ុស្តិ៍នគរបាលព្រំដែនបន្ទាយចក្រី ចំណុះវរៈសេនាតូចនគរបាលការពារព្រំដែនលេខ ៦០៧ មានទំហំ ៥ ២៩៨ ម៉ែត្រក្រឡា ស្ថិតនៅភូមិគោ ឃុំបន្ទាយចក្រី ស្រុកព្រះស្តេច ខេត្តព្រៃវែង។

-ទីតាំងដីមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មអ្នកជំងឺរបួសខួរឆ្អឹងខ្នង មានទំហំ ១០ ០០០ ម៉ែត្រក្រឡា ស្ថិតនៅភូមិចំការសំរោង២ សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបង និងទីតាំងសំណង់អគារផ្ទះចាស់១ល្វែង មានដីទំហំ ១១៧ ម៉ែត្រក្រឡា ស្ថិតនៅសង្កាត់ស្វាយប៉ោ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

**មាត្រា២.-**

ការលុបទីតាំងដូចមានចែងក្នុងមាត្រា១ ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រូវស្ថិតក្រោមការចាត់ចែងតាមនីតិវិធី ដោយក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**មាត្រា ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីរដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ ទៅជា វិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

ត្រូវបានប្រែក្លាយមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ទៅជាវិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់សរសេរជាអក្សរកាត់ថា **វ.ព.ព.ស.** និងជាភាសាអង់គ្លេសថា **Polytechnic Institute of Pursat Province** សរសេរជាអក្សរកាត់ថា **P.I.P.P.**។

**មាត្រា២ ._**

**វ.ព.ព.ស.** ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**វ.ព.ព.ស.** មានទីតាំងស្ថិតនៅភូមិចំការចេកខាងត្បូង សង្កាត់ផ្ទះព្រៃ ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

## ជំពូកទី២

## តួនាទីនិងភារកិច្ច

**មាត្រា៣ ._**

**វ.ព.ព.ស.** មានតួនាទីជាសេនាធិការឲ្យក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានភារកិច្ចដូចខាងក្រោម៖

- អភិវឌ្ឍកម្មវិធីអប់រំ និងបណ្តុះបណ្តាលស្របតាមស្តង់ដាសមត្ថភាព កម្រិតគុណវុឌ្ឍិជាតិ និងតម្រូវការទីផ្សារការងារ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍរបស់វិទ្យាស្ថានរយៈពេលខ្លី មធ្យម និងវែង
- សិក្សា ស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សាជាតិ និងអន្តរជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា
- លើកកម្ពស់សមត្ថភាពជំនាញបច្ចេកទេស និងប្រឹក្សាយោបល់ដល់មន្ត្រី និងគ្រូបច្ចេកទេស
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់កិច្ចដំណើរការរបស់វិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន គ្រូបច្ចេកទេស កម្មករ សិក្ខាកាម សិស្ស និស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន
- កៀរគរធនធានពីប្រភពផ្សេងៗទៀតសម្រាប់ការបណ្តុះបណ្តាលនិងការសិក្សាស្រាវជ្រាវ
- ជ្រើសរើសសិក្ខាកាម សិស្ស និស្សិតឲ្យចូលរៀនតាមការកំណត់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- អនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា៤ ._**

**វ.ព.ព.ស.** ធ្វើការបណ្តុះបណ្តាលដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិលើកម្រិតជំនាញដូចខាងក្រោម៖

- កម្រិតវិញ្ញាបនបត្រវិជ្ជាជីវៈ សិក្សារយៈពេលខ្លីក្រោម១ឆ្នាំ ទៅតាមជំនាញវិជ្ជាជីវៈ
- កម្រិតសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ ២ និង៣ សិក្សារយៈពេល១ឆ្នាំ ២ឆ្នាំ និង៣ឆ្នាំ ដែលមានយ៉ាងតិច៣០ក្រេឌីត(សម្រាប់មួយកម្រិត)/

- កម្រិតសញ្ញាបត្រជាន់ខ្ពស់/បរិញ្ញាបត្ររង បច្ចេកទេស/ឯកទេស សិក្សារយៈពេលយ៉ាងតិច២ឆ្នាំ ដែលមានយ៉ាងតិច៦០ក្រេឌីត
- កម្រិតបរិញ្ញាបត្របច្ចេកវិទ្យា/ឯកទេសសញ្ញាបត្រវិស្វករ សិក្សារយៈពេលយ៉ាងតិច៤ឆ្នាំ ដែលមានយ៉ាងតិច១២០ក្រេឌីត។

យន្តការ នីតិវិធី និងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៥ .–**

**វ.ព.ព.ស.** ត្រូវដឹកនាំដោយនាយក១(មួយ)រូប តែងតាំងដោយអនុក្រឹត្យ និងនាយករងមួយចំនួនតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុលោមតាមបទប្បញ្ញត្តិ ជាធរមាន។

**វ.ព.ព.ស.** មានដេប៉ាតឺម៉ង់ និងការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់ និងការិយាល័យចំណុះ **វ.ព.ព.ស.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៦ .–**

**វ.ព.ព.ស.** មានក្រុមប្រឹក្សាបច្ចេកទេសមួយដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីសិក្សារបស់ **វ.ព.ព.ស.**។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៧ .–**

**វ.ព.ព.ស.** អាចមានទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ និងអន្តរជាតិមួយចំនួនសម្រាប់ជួយបំពេញការងារ។

**មាត្រា៨ .–**

**វ.ព.ព.ស.** មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៩ .–**

សិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានវិញ្ញាបនបត្រ ឬ សញ្ញាបត្រតាមកម្រិត និងឯកទេសដែលបានសិក្សា។ វិញ្ញាបនបត្រឬសញ្ញាបត្រនេះត្រូវផ្តល់ឲ្យដោយ **វ.ព.ព.ស.** និងត្រូវទទួលស្គាល់ពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា១០ .–**

ការចំណាយសម្រាប់ដំណើរការរបស់ **វ.ព.ព.ស.** ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**វ.ព.ព.ស.** មានសិទ្ធិទទួល ចាត់ចែង និងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាន នូវមូលនិធិដែលបានមកពីប្រភពផ្សេងៗទៀតសម្រាប់ដំណើរការងាររបស់ខ្លួន។

**មាត្រា១១ .-**

មន្ត្រីរាជការដែលបាន និងកំពុងបំពេញការងារនៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្តពោធិ៍សាត់ ត្រូវផ្ទេរទៅបម្រើការងារនៅ **វ.ព.ព.ស.** ដោយរក្សាទុកតួនាទីដដែលរហូតដល់មានការតែងតាំងសារជាថ្មី ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៤
## អវសានបញ្ញត្តិ

**មាត្រា១២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ២ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តពោធិ៍សាត់
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦១៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនព្រះតេជគុណ កុង ពិសី ព្រះគ្រូចៅអធិការវត្តសំបួរមាស ដែលបានឧបត្ថម្ភថវិកាចំនួន ៧៦.០០០ ដុល្លារអាមេរិក ជួយកសាងអគារសិក្សា ០១ ខ្នង ជូនសាលាបឋមសិក្សាសំបួរមាស ក្នុងរាជធានីភ្នំពេញ។

**មាត្រា២.**_រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១៥កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៦១៨ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សម្រេច

**មាត្រា១.**.បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនបុគ្គលិកអប់រំនៅថ្នាក់ជាតិ ចំនួន ២២២ គ្រឿង ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ ទទួលបានលទ្ធផល ល្អប្រសើរ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | | | | |
|---|---|---|---|---|---|
| ១ | លោក | **ភាន់** | **ពុទ្ធី** | អនុប្រធាន | នាយកដ្ឋានបឋមសិក្សា |
| ២ | លោក | **មាស** | **តា** | ប្រធានការិយាល័យរដ្ឋបាល | នាយកដ្ឋានឧត្តមសិក្សា |
| ៣ | លោក | **សៅ** | **ឌូ** | ប្រធានការិយាល័យអធិការកិច្ច | នាយកដ្ឋានឧត្តមសិក្សា |
| ៤ | លោកស្រី | **យក់** | **បញ្ញាភី** | ប្រធានការិយាល័យ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៥ | លោក | **ឡើក** | **ពិដោរ** | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៦ | លោកស្រី | **ឡុច** | **ល័ក្ខស្មី** | ប្រធានដេប៉ាតឺម៉ង់ភាសាជប៉ុន | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៧ | លោក | **សំបូរ** | **មាណ្ណារ៉ា** | អនុប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨ | លោកស្រី | **សំរិត** | **សុធ្ធា** | ប្រធានដេប៉ាតឺម៉ង់ភាសាវិទ្យា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩ | លោក | **ថោង** | **រឌ្យិ** | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១០ | លោក | **ឆាង** | **ប៉ាង** | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

| | | | | | |
|---|---|---|---|---|---|
| ១១ | លោកស្រី | គិម | ផារិន | មន្ត្រីការិយាល័យសិក្សា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១២ | លោកស្រី | អែម | សុគន្ធា | មន្ត្រីការិយាល័យសិក្សា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៣ | លោក | អន | សុខុឌ្ឍី | មន្ត្រីការិយាល័យគណនេយ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៤ | លោក | តូច | តាព | ព្រឹទ្ធបុរសមហាវិទ្យាល័យ | សាកលវិទ្យាល័យជាស៊ីមកំចាយមារ |
| ១៥ | លោក | ទិត | រ៉ាទី | ព្រឹទ្ធបុរសមហាវិទ្យាល័យ | សាកលវិទ្យាល័យជាស៊ីមកំចាយមារ |
| ១៦ | លោក | ហូច | សុឃុន | ព្រឹទ្ធបុរសមហាវិទ្យាល័យ | សាកលវិទ្យាល័យស្វាយរៀង |
| ១៧ | លោកស្រី | សួន | ផល្លា | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | សាកលវិទ្យាល័យស្វាយរៀង |
| ១៨ | លោក | ពិន | តារា | សាកលវិទ្យាធិការរង | សាកលវិទ្យាល័យ ហេង សំរិនត្បូងឃ្មុំ |
| ១៩ | លោក | សំ | រ៉ានី | សាកលវិទ្យាធិការរង | សាកលវិទ្យាល័យបាត់ដំបង |
| ២០ | លោក | ជា | រដ្ឋា | ប្រធានការិយាល័យ | សាកលវិទ្យាល័យបាត់ដំបង |
| ២១ | លោក | ប្រាក់ | ចិត្រា | អនុប្រធានលេខាធិការដ្ឋាន | អគ្គនាយកដ្ឋានយុវជន |
| ២២ | លោក | ហេង | ច័ន្ទសុវណ្ណ | ប្រធានការិយាល័យរដ្ឋបាល | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២៣ | លោក | តាល់ | វណ្ណារ៉ា | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ២៤ | លោកស្រី | ហេង | អញ្ញា | ប្រធានការិយាល័យអាស៊ាន | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន |
| ២៥ | លោកស្រី | ឯម | ផល្លា | មន្ត្រីការិយាល័យបច្ចេកទេស | នាយកដ្ឋានសុខភាពសិក្សា |
| ២៦ | លោក | អ៊ុយ | ចិសិទ្ធ | អនុប្រធានការិ.ផែនការ | នាយកដ្ឋានសុខភាពសិក្សា |
| ២៧ | លោកស្រី | គីត | វណ្ណារេត | ប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ២៨ | លោកស្រី | គង់ | សុតាវត្តី | ប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ២៩ | លោកស្រី | លី | សាខុន | អនុប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ៣០ | លោក | អ៊ុក | ម៉ុនធឿន | អនុប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ៣១ | លោកស្រី | ចិន | ណារី | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិត |
| ៣២ | លោក | អួន | សុគន្ធី | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំកាយនិងកីឡាសិស្ស-និស្សិត |
| ៣៣ | លោក | ម៉ែត | សុផលរឹទ្ធិ | ប្រធានការិយាល័យ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| ៣៤ | លោក | ឡាយ | សុខធី | អនុប្រធានការិយាល័យ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ៣៥ | លោក | ជា | កុសល | អនុប្រធានការិយាល័យ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ៣៦ | លោក | ឈា | សាហុន | អនុប្រធានការិយាល័យ | នាយកដ្ឋានធានាគុណភាពអប់រំ |
| ៣៧ | លោក | ម៉ុច | ទី | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋាននីតិកម្ម |
| ៣៨ | លោក | អ៊ុក | សារ៉ាត់ | ប្រធានការិយាល័យ | នាយកដ្ឋានហិរញ្ញវត្ថុ |
| ៣៩ | លោក | គីម | ថាច | មន្ត្រីការិយាល័យរដ្ឋបាល | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |

| | | | | | |
|---|---|---|---|---|---|
| ៤០ | លោក | ជន | សារ៉ែន | មន្ត្រីការិយាល័យរដ្ឋបាល | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| ៤១ | លោក | វង់ | សុខឡុ | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤២ | លោក | នុង | សម្បត្តិ | មន្ត្រីការិយាល័យ | នាយកដ្ឋានរដ្ឋបាល |
| ៤៣ | លោក | ផេង | សុខលី | អនុប្រធានការិយាល័យ | នាយកដ្ឋានរដ្ឋបាល |
| ៤៤ | លោកស្រី | សេង | ស៊ីណែត | អនុប្រធាននាយកដ្ឋាន | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ៤៥ | លោកស្រី | ឌុត | ផល្លីនី | អនុប្រធានការិយាល័យសិក្សា | វិទ្យាស្ថានជាតិអប់រំ |
| ៤៦ | លោក | បាន | គនហេង | អនុប្រធានការិយាល័យ | វិទ្យាស្ថានជាតិអប់រំ |
| ៤៧ | លោក | ម៉ូ | ម៉ិន្តន | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៤៨ | លោក | អ៊ុត | សិរីសុខត្ថិ | គ្រូបង្រៀន | វិទ្យាស្ថានជាតិអប់រំ |
| ៤៩ | លោកស្រី | ហុង | សុផារី | គ្រូបង្រៀន | វិទ្យាស្ថានជាតិអប់រំ |
| ៥០ | លោក | យ៉ែម | ម៉ៃ | អនុប្រធានការិយាល័យ | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា |
| ៥១ | លោក | ស្រី | ស៊ីថត្ថា | អនុប្រធានការិយាល័យរដ្ឋបាល | មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា |
| ៥២ | លោក | អ៊ុំ | សុផាណារ៉ូ | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំកាយ និងកីឡា |
| ៥៣ | លោក | អ៊ូច | គួច | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំកាយ និងកីឡា |
| ៥៤ | លោកស្រី | រ័ត្ន | ម៉ារិន | ប្រធានការិយាល័យ | នាយកដ្ឋានអប់រំកុមារតូច |

**ខ-មេដាយប្រាក់ការងារ**

| | | | | | |
|---|---|---|---|---|---|
| ១ | លោក | ស្រួយ | ផានិត | មន្ត្រីការិយាល័យ | ខុទ្ទកាល័យ |
| ២ | លោកស្រី | ម៉ុនរី | រីនណា | អនុប្រធានការិយាល័យ | នាយកដ្ឋានឧត្តមសិក្សា |
| ៣ | លោក | ភាក់ | រចនា | អនុប្រធានការិយាល័យ | នាយកដ្ឋានឧត្តមសិក្សា |
| ៤ | លោក | ឆាយ | ពៅ | អនុប្រធានការិយាល័យ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៥ | លោក | គង់ | សុភ័ក្រ | មន្ត្រីការិយាល័យ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៦ | លោក | ឆា | ម៉ាន់ថា | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៧ | លោក | អ៊ុង | ម៉ុនអ៊ី | ប្រធានស្តីទីដេប៉ាតឺម៉ង់ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៨ | លោកស្រី | ជា | អេលីយ៉ាន | អនុប្រធានដេប៉ាតឺម៉ង់បរិស្ថាន | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ៩ | លោក | ថាន់ | ម៉េងលាប | ប្រធានស្តីទីការិយាល័យបុគ្គលិក | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១០ | លោក | ហ៊ិន | ធីរិទ្ធ | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១១ | លោកស្រី | ណេរា | ច័ន្ទនី | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១២ | លោកស្រី | ឡុង | ចាន់ដាវី | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៣ | លោកស្រី | ថ្មាំ | សូរីយ៉ា | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |

| | | | | | |
|---|---|---|---|---|---|
| ១៤ | លោក | ថាច់ | ម៉ិច | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៥ | លោក | ហាម | គឹមគង់ | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៦ | លោក | ខាន់ | ប៊ុផាន់ | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៧ | លោក | ពូយ | ឃាង | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៨ | លោក | សុខ | លីមស្រ៊ន់ | សាស្ត្រាចារ្យ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ១៩ | លោកស្រី | ណៃ | សាឡឿន | បុគ្គលិកការិយាល័យរដ្ឋបាល | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| ២០ | លោក | ខែម | ថាន | ព្រឹទ្ធបុរសរង | សាកលវិទ្យាល័យជាស៊ីម កំចាយមារ |
| ២១ | លោក | ណៃ | ដំណែរល | ប្រធានការិយាល័យហិរញ្ញវត្ថុ | សាកលវិទ្យាល័យជាស៊ីម កំចាយមារ |
| ២២ | លោក | គង់ | ណារិន | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | សាកលវិទ្យាល័យជាស៊ីម កំចាយមារ |
| ២៣ | លោក | ម៉ុំ | អេត | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | សាកលវិទ្យាល័យស្វាយរៀង |
| ២៤ | លោក | ឃុន | រតនា | សាស្ត្រាចារ្យ | សាកលវិទ្យាល័យស្វាយរៀង |
| ២៥ | លោក | ចាន់ | ផារិទ្ធិ | សាស្ត្រាចារ្យ | សាកលវិទ្យាល័យស្វាយរៀង |
| ២៦ | លោក | ទ៉ា | សុភ័ក្រ្ត | គ្រូកម្រិតឧត្តម | សាកលវិទ្យាល័យ ហេង សំរិនត្បូងឃ្មុំ |
| ២៧ | លោកស្រី | ហាច | ហួន | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | សាកលវិទ្យាល័យបាត់ដំបង |
| ២៨ | លោក | ឌួន | ឌូ | អនុប្រធានដេប៉ាតឺម៉ង់ | សាកលវិទ្យាល័យបាត់ដំបង |
| ២៩ | លោក | សោ | ទ៉ាន់ហ៊ីត | អនុប្រធានការិយាល័យសិក្សា | សាកលវិទ្យាល័យបាត់ដំបង |
| ៣០ | លោក | ទ៉ោ | ទិមុល | អនុប្រធានការិយាល័យ | នាយកដ្ឋានរដ្ឋបាល |
| ៣១ | លោក | ពៅ | សុខ | អនុប្រធានការិយាល័យ | នាយកដ្ឋានរដ្ឋបាល |
| ៣២ | លោក | ឡេ | សុឃឿន | អនុប្រធានការិយាល័យ | នាយកដ្ឋានរដ្ឋបាល |
| ៣៣ | លោក | សុខ | គឿន | អនុប្រការិយាល័យ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣៤ | លោក | សែម | ឡាង | មន្ត្រីការិយាល័យរដ្ឋបាល | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣៥ | លោក | ឡុង | សុផាត | អនុប្រការិយាល័យ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៣៦ | លោក | ថោង | ថន | អនុប្រធានការិយាល័យអាស៊ាន | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន |
| ៣៧ | លោក | ផាន់ | សុតា | អនុប្រធានការិយា ស៊ីមីអូ | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន |
| ៣៨ | លោកស្រី | ពេជ | សុគន្ធា | មន្ត្រីការិយាល័យ | នាយកដ្ឋានសុខភាពសិក្សា |
| ៣៩ | លោក | ប៉ាក | ម៉ិនថន | មន្ត្រីការិយាល័យ | នាយកដ្ឋានសុខភាពសិក្សា |
| ៤០ | លោកស្រី | ភាន់ | សុធារី | មន្ត្រីការិយាល័យ | នាយកដ្ឋានសុខភាពសិក្សា |
| ៤១ | លោក | ឡឹម | ឌុទ្ធី | មន្ត្រីការិយាល័យ | នាយកដ្ឋានសុខភាពសិក្សា |
| ៤២ | លោក | ភាន់ | ពុទ្ធី | ប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |

| | | | | | |
|---|---|---|---|---|---|
| ៤៣ | លោក | ទ្រាំ | ធិរម្យ | ប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ៤៤ | លោក | ជា | ចាន់ធិ | ប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ៤៥ | លោកស្រី | យក់ | វណ្ណា | ប្រធានការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ៤៦ | លោកស្រី | ឆេង | ផលនី | មន្ត្រីការិយាល័យ | នាយកដ្ឋានបឋមសិក្សា |
| ៤៧ | លោក | មាស | សារ៉េត | មន្ត្រីការិយាល័យទីលាន | នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត |
| ៤៨ | លោក | អៀ | សាខន | មន្ត្រីការិយាល័យផែនការ | នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស-និស្សិត |
| ៤៩ | លោក | ឡេង | ស៊ីវណ្ណដុល្លា | ប្រធានការិយាល័យ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |
| ៥០ | លោក | ហាន | រដ្ឋា | អនុប្រធានការិយាល័យ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ៥១ | លោក | ម៉ៅ | ស៊ុយពិសិដ្ឋ | អនុប្រធានការិយាល័យ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ៥២ | លោក | ព្រីង | សុវណ្ណ | អនុប្រធានការិយាល័យ | នាយកដ្ឋានធានាគុណភាពអប់រំ |
| ៥៣ | លោក | អ្នត | សុខា | អនុប្រធានការិយាល័យ | នាយកដ្ឋានធានាគុណភាពអប់រំ |
| ៥៤ | លោក | រស់ | សុឆាន់ | អនុប្រធានការិយាល័យ | នាយកដ្ឋាននីតិកម្ម |
| ៥៥ | លោកស្រី | ទូន | សុខចេង | ប្រធានការិយាល័យ | នាយកដ្ឋានហិរញ្ញវត្ថុ |
| ៥៦ | លោក | នុត | ណៃភត | មន្ត្រីការិយាល័យ | នាយកដ្ឋានហិរញ្ញវត្ថុ |
| ៥៧ | លោក | ស៊ឹង | សុវឌ្ឍ | មន្ត្រីការិយាល័យ | នាយកដ្ឋានហិរញ្ញវត្ថុ |
| ៥៨ | លោស្រី | សុខ | សោភ័ណ្ឌ | មន្ត្រីការិយាល័យ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ |
| ៥៩ | លោក | អ៊ុត | សម្ផស្ស | អនុប្រការិយាល័យ | នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន |
| ៦០ | លោក | ឃាង | ម៉េងលី | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦១ | លោកស្រី | ឈឹម | ភាវី | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦២ | លោកស្រី | ជា | កល្យាណា | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦៣ | លោក | គឹម | ចំរើនឧត្តរី | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦៤ | លោក | ឡុច | ចាន់ថន | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦៥ | លោក | នី | រដ្ឋា | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦៦ | លោក | នៃ | សុផល | គ្រូឧទ្ទេស | វិទ្យាស្ថានជាតិអប់រំ |
| ៦៧ | លោកស្រី | ទេព | សុវណ្ណារី | គ្រូបង្រៀន | វិទ្យាស្ថានជាតិអប់រំ |
| ៦៨ | លោក | ឈុំ | ប៊ុនធឿន | មន្ត្រីការិយាល័យរដ្ឋបាល | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា |
| ៦៩ | លោក | ហួត | ពៅលក្ខិណា | គ្រូបង្រៀន | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា |
| ៧០ | លោក | ឃួន | ណារិទ្ធិ | អនុប្រធានការិ.បណ្តុះបណ្តាល | មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា |
| ៧១ | លោកស្រី | ហង់ | ស៊ីមន | អនុប្រធានការិយាល័យព័ត៌មាន | មជ្ឈមណ្ឌលហ្វឹកហ្វឺនកីឡា |

| | | | | | |
|---|---|---|---|---|---|
| ៧២ | លោកស្រី | គង់ | សំរ៉ាំង | អនុប្រធានការិយាល័យរដ្ឋបាល | នាយកដ្ឋានអប់រំកាយ និងកីឡា |
| ៧៣ | លោក | ផែង | ចាន់ណា | មន្ត្រីការិយាល័យរដ្ឋបាល | នាយកដ្ឋានអប់រំកាយ និងកីឡា |
| ៧៤ | លោក | អ៊ុក | សុខ | មន្ត្រីការិ.ផែនការ ហិរញ្ញវត្ថុ | នាយកដ្ឋានអប់រំកាយ និងកីឡា |
| ៧៥ | លោកស្រី | ឃុន | ម៉េងហេង | មន្ត្រី | នាយកដ្ឋានអប់រំកាយ និងកីឡា |
| ៧៦ | លោកស្រី | អ៊ឹម | សុផានី | ប្រធានការិយាល័យ | នាយកដ្ឋានអប់រំកុមារតូច |
| ៧៧ | លោកស្រី | សុខ | សោភា | ប្រធានការិយាល័យ | នាយកដ្ឋានអប់រំកុមារតូច |
| ៧៨ | លោក | ឆន | ឈាង | អនុប្រធានការិយាល័យ | នាយកដ្ឋានអប់រំកុមារតូច |

## គ-មេដាយសំរឹទ្ធការងារ

| | | | | | |
|---|---|---|---|---|---|
| ១ | លោក | ផុន | សាមាន | អនុប្រធានការិយាល័យរដ្ឋបាល | នាយកដ្ឋានឧត្តមសិក្សា |
| ២ | លោក | តាំង | ឆាយហួត | អនុប្រធានការិយាល័យ | នាយកដ្ឋានឧត្តមសិក្សា |
| ៣ | លោកស្រី | សៀ | នីយ៉ា | មន្ត្រីការិយាល័យអធិការកិច្ច | នាយកដ្ឋានឧត្តមសិក្សា |
| ៤ | លោក | ជួន | ម៉ុនធី | មន្ត្រីការិយាល័យ | សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
| ៥ | លោក | ស៊ឹម | ទ្រី | មន្ត្រីការិយាល័យ | សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច |
១១៣-វរសេនីយ៍ទោ **តាំង អៀង** អត្តលេខ ០៦៧៦៥៥ នាយរងការិយាល័យបង្ការទប់ស្កាត់ជំងឺអេដស៍ នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១១៤-វរសេនីយ៍ទោ **ស៊ូ ហុង** អត្តលេខ ០១៤៣០៣ នាយរងការិយាល័យឱសថ នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១១៥-វរសេនីយ៍ទោ **ជា សូលីដា**(នារី) អត្តលេខ ០២៤២៣៧ នាយរងឃ្លាំងឱសថ នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១១៦-វរសេនីយ៍ទោ **ម៉ៅ ស៊ុនលី** អត្តលេខ ០២៥២៤៨ នាយរងការិយាល័យធានា នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១១៧-វរសេនីយ៍ទោ **នូវ សម្បត្តិ** អត្តលេខ ២២៩៩៦៤ នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១១៨-វរសេនីយ៍ទោ **សេក កុសេម**(នារី) អត្តលេខ ០៥៧៩៨៩ នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១១៩-វរសេនីយ៍ទោ **ធីម ណារិទ្ធ** អត្តលេខ ០៣៩៥៩៧ នាយរងការិយាល័យបង្គប្រភព នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២០-វរសេនីយ៍ទោ **ជា ហួរ** អត្តលេខ ០២៥២៤០ នាយរងការិយាល័យបង្គប្រភព នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២១-វរសេនីយ៍ទោ **សឹង ឡាយ** អត្តលេខ ០១៩៩៧៤ នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២២-វរសេនីយ៍ទោ **សៅ សុខឃីម** អត្តលេខ ០១៤៥៥៣ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានប្រេងឥន្ធនៈអគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២៣-វរសេនីយ៍ទោ **តុប សាវន** អត្តលេខ ០៣៥០៤៥ នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២៤-វរសេនីយ៍ទោ **ប្រុក គីមស្រេង**អត្តលេខ ០២៥២៥៥ នាយរងការិយាល័យបច្ចេកទេស នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២៥-វរសេនីយ៍ទោ **យឹម វិបុល** អត្តលេខ ០៣២២០៨ នាយរងការិយាល័យផែនការ នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២៦-វរសេនីយ៍ទោ **កែវ** **សំអុល** អត្តលេខ ០០៨៦១៦ នាយរងការិយាល័យធានា នាយកដ្ឋានប្រេងឥន្ធនៈ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១២៧-វរសេនីយ៍ទោ **ហាស់** **មុន្នីរ័ត្ន** អត្តលេខ ០៣៩៥៦៤ នាយផ្នែកពិធីការ នាយកដ្ឋានអភិវឌ្ឍន៍

១២៨-វរសេនីយ៍ទោ **ផន** **ភាត** អត្តលេខ ០១៩៧៩៥ ជំនួយការ ឯកឧត្តម **នាង ផាត** រដ្ឋលេខាធិការ ក្រសួងការពារជាតិ

១២៩-វរសេនីយ៍ទោ **ឡាញ់** **ទិដ្ឋ័យ** អត្តលេខ ០៤៣១៥២ ជំនួយការ ឯកឧត្តម **ឡាញ់ នី**

១៣០-វរសេនីយ៍ទោ **ស្រី** **ទីរៈ** អត្តលេខ ០៤៦៣២៨ ជំនួយការ ឯកឧត្តម ចៅ ផល្លី អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

១៣១-វរសេនីយ៍ទោ **ថោខ** **ចិន្តា** អត្តលេខ ០២៣៤៤៨ នាយរងការិយាល័យព័ត៌មាន នាយកដ្ឋានព័ត៌មាន និងគ្រប់គ្រងស្ថានីយ៍ អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិទប់ស្កាត់អាវុធគីមីនុយក្លេអ៊ែរ ជីវសាស្ត្រ និងវិទ្យុសកម្ម

១៣២-វរសេនីយ៍ទោ **ធីក** **ថាវខេ្យ** អត្តលេខ ០៣១៨៤៦ ជំនួយការ ឯកឧត្តម **នាង ផាត** រដ្ឋលេខាធិការ ក្រសួងការពារជាតិ

១៣៣-វរសេនីយ៍ទោ **ម៉ុន** **ធឿន** អត្តលេខ ០២៤៩៨០ នាយរងការិយាល័យទទួលពាក្យបណ្តឹង នាយកដ្ឋានអធិការកិច្ច

១៣៤-វរសេនីយ៍ទោ **អ៊ុត** **ហោ** អត្តលេខ ០១៤០៨៣ នាយរងការិយាល័យគ្រឿងញៀន នាយកដ្ឋានអធិការកិច្ច

១៣៥-វរសេនីយ៍ទោ **សឹម** **វ៉ាត** អត្តលេខ ០១៤០៦៩ នាយរងការិយាល័យកងទ័ពជើងគោក នាយកដ្ឋានអធិការកិច្ច

១៣៦-វរសេនីយ៍ទោ **សេក** **សុផុន** អត្តលេខ ០១៤០៥១ នាយរងការិយាល័យស្ថាប័ន អង្គភាពចំណុះ នាយកដ្ឋានអធិការកិច្ច

៦៤-វរសេនីយ៍ទោ **គឹម** **និរុត្ត** អត្តលេខ ០២៤០២០ នាយករង សាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុជាតិ មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាម

១៣៨-វរសេនីយ៍ទោ **ឆួន** **សេរីរ័ត្ន** អត្តលេខ ០២៥៣៣៦ នាយរងមន្ទីរឃុំឃាំង ស្ថាប័នអយ្យការយោធា

១៣៩-វរសេនីយ៍ទោ **ម៉ៅ** **ធៀម** អត្តលេខ ០៣៥០១២ នាយរងលេខាធិការដ្ឋាន នាយដ្ឋានយានយន្ត អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

១៤០-វរសេនីយ៍ទោ **នៅ** **រិទ្ធីយ៉ា** អត្តលេខ ០៥៣៨៩២ នាយភស្តុភារ ហិរញ្ញវត្ថុ នាយកដ្ឋានផែនការ អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស

១៤១-វរសេនីយ៍ទោ **សោម** **ភាស្នេរ** អត្តលេខ ០៤៨៤៩១ នាយផ្នែកតាមដានធានា នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៤២-វរសេនីយ៍ទោ **ឆាយ** **ម៉ូរ៉ា** អត្តលេខ ០៤៨៤៧៦ នាយរងការិយាល័យផែនការ នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៤៣-វរសេនីយ៍ទោ **សុខ** **ចណ្ណី** អត្តលេខ ០៤៧៩០២ នាយរងលេខាធិការដ្ឋាន នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៤៤-វរសេនីយ៍ទោ **ធីម** **រតនៈ** អត្តលេខ ១៦៣១០៣ នាយរងការិយាល័យស្បៀង នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៤៥-វរសេនីយ៍ទោ **ញឹម** **ម៉ូលីសុគីណា** អត្តលេខ ២១០១៩៣ នាយរងការិយាល័យផែនការ នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៤៦-វរសេនីយ៍ទោ **លន់ ហាក់** អត្តលេខ ០៦៨៥៣០ នាយរងការិយាល័យបច្ចេកទេស
ស្ថាប័នអយ្យការយោធា

១៤៧-វរសេនីយ៍ទោ **ណៃ សុមង្គល** អត្តលេខ ០៦៨៤៤៧ ជំនួយការ ឯកឧត្តម នាយករង
ស្ថាប័នអយ្យការយោធា

១៤៨-វរសេនីយ៍ទោ **ជិន ម៉ៅ** អត្តលេខ ០២៥៣០៣ នាយការិយាល័យបច្ចេកទេស
ស្ថាប័នអយ្យការយោធា

១៤៩-វរសេនីយ៍ទោ **ផាន់ ស៊ីថា** អត្តលេខ ០៣១៥០៦ នាយអគារផ្នែក
មន្ទីរពេទ្យព្រះកេតុមាលា អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៥០-វរសេនីយ៍ទោ **ខៀង ស៊ុន** អត្តលេខ ០៥៨៣៥៣ នាយរងការិយាល័យស្បៀង
នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៥១-វរសេនីយ៍ទោ **អ៊ូ ទិចិត្រ** អត្តលេខ ០៥០៦៩៦ នាយផ្នែកផែនការ យោធបរិក្ខារ
នាយកដ្ឋានផ្គត់ផ្គង់ អគ្គនាយកដ្ឋានភស្តុភារ ហិរញ្ញវត្ថុ

១៥៣-វរសេនីយ៍ទោ **ពីខ ហោខ** អត្តលេខ ០២៥១៣២ នាយរងការិយាល័យបច្ចេកទេស
ព្រំដែន នាយកដ្ឋានភូមិសាស្ត្រ

១៥៣-វរសេនីយ៍ទោ **ម៉ឺខ ពិសិដ្ឋ** អត្តលេខ ០៥៨២៥៦ នាយលេខាធិការដ្ឋាន
នាយកដ្ឋានភូមិសាស្ត្រ

១៥៤-វរសេនីយ៍ទោ **ឈៀខ សុខមេត្តា** អត្តលេខ ០២២៨២១ នាយការិយាល័យហ្វឹកហ្វឺន
នាយកដ្ឋានភូមិសាស្ត្រ

១៥៥-វរសេនីយ៍ទោ **ម៉ម សុវណ្ណានី** អត្តលេខ ០២០៤៩៦ នាយប្រវត្តិសាស្ត្រយោធា
នាយកដ្ឋានភូមិសាស្ត្រ

១៥៦-វរសេនីយ៍ទោ **ខៀវ ខេមរិន្ទ** អត្តលេខ ០០១៦៥០ នាយរងការិយាល័យវាស់វែង
នាយកដ្ឋានភូមិសាស្ត្រ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១៥កើត ខែ បឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**អន្លែខទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :៦១៩.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា១..** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន៣រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានា រួមមានព្រះវិហារ សាលាធម្មសភា ០១ខ្នង បន្ទប់ទឹក បង្គោលភ្លើង នៅវត្តប្រាំបីមុំ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ សរុបទឹកប្រាក់ចំនួន ១១៥.៧០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

-លោកជំទាវ **សេង ពុទ្ធិនាគ**

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

១-លោកជំទាវ **ឆេត វន្ធា**

២-លោកជំទាវ **ឆេត បូរ៉ាមីន**

**មាត្រា២..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស អភិបាលនៃគណៈអភិបាលខេត្តតាកែវ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ៧ ៨ ១៥កើត ខែ បឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨
នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ៦២០.អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរបញ្ចូល និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជាក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** : ផ្ទេរបញ្ចូលលោក **ម៉ែន ចាន់រ៉ា** ពីឋានន្តរស័ក្តិវរសេនីយ៍ទោ នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា មកក្នុងឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ។

**មាត្រា ២** : និយ័តកម្មតម្លើងឋានន្តរស័ក្តិ និងថ្នាក់ជូនមន្ត្រីរាជការចំនួន ០៣រូប ដូចមានរាយនាមខាងក្រោមៈ

១-លោក **ឡៀម សំអាត** ពីឋានន្តរស័ក្តិក្រមការដើមខ្សែ ថ្នាក់លេខ៣ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

២-លោក **ឈឺន សុខជា** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៣ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦

៣-លោក **ហ៊ី ម៉ុនថន** ពីឋានន្តរស័ក្តិក្រមការ ថ្នាក់លេខ៣ មកជាឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ៦។

**មាត្រា ៣** : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ និងមាត្រា ២ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ុ៦ ១៥ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៦២១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ តម្លើងឋានន្តរស័ក្តិ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

១- វរសេនីយ៍ទោ **គីម រតនា** អត្តលេខ ០៣០០៣
២- វរសេនីយ៍ទោ **ថន ណារ៉ា** អត្តលេខ ០៣៩០៩
៣- វរសេនីយ៍ទោ **ពៅ សារឿន** អត្តលេខ ០៤៥៨១
៤- វរសេនីយ៍ទោ **ឱត្យ ម៉ៅ** អត្តលេខ ០៤៨៣០
៥- វរសេនីយ៍ទោ **កែ ឡឿន** អត្តលេខ ០៥៣៧៣
៦- វរសេនីយ៍ទោ **សុខ ម៉ាក់** អត្តលេខ ០៥៥១៧
៧- វរសេនីយ៍ទោ **នៅ ណាន** អត្តលេខ ០៥៧៦១
៨- វរសេនីយ៍ទោ **ម៉ន ណាក់** អត្តលេខ ០៦៣៣៣
៩- វរសេនីយ៍ទោ **នង ថាណារី** អត្តលេខ ០៦៤៩៤
១០- វរសេនីយ៍ទោ **ស សុធា** អត្តលេខ ០៧១៧២

១១- វរសេនីយ៍ទោ **ពុទ្ធា ធីរៈនារី** អត្តលេខ ០៨១១៨

១២- វរសេនីយ៍ទោ **ជឹម ធន់** អត្តលេខ ០៨៩៩១

១៣- វរសេនីយ៍ទោ **ហោ សុគ័ន្ធ** អត្តលេខ ១១២៤១

១៤- វរសេនីយ៍ទោ **ហេង នី** អត្តលេខ ១២១៥៤

១៥- វរសេនីយ៍ទោ **ឈួន សារ៉េត** អត្តលេខ ១២២២៤

១៦- វរសេនីយ៍ទោ **យោគ ស៊ីថុន** អត្តលេខ ១៣៨១៥

១៧- វរសេនីយ៍ទោ **ទូច ទាសនា** អត្តលេខ ១៦០៨៥

១៨- វរសេនីយ៍ទោ **កែម តាយ** អត្តលេខ ១៦៣០០

១៩- វរសេនីយ៍ទោ **តុប ចន្ថា** អត្តលេខ ១៦៥៨៦

២០- វរសេនីយ៍ទោ **អ៊ូ ដារ៉ាឧុធ** អត្តលេខ ១៧៤៤៥

២១- វរសេនីយ៍ទោ **សោម ច័ន្ទណារិទ្ធ** អត្តលេខ ១៧៤៧៩

២២- វរសេនីយ៍ទោ **ផាត ចាន់ថុល** អត្តលេខ ២៧០៣២

២៣- វរសេនីយ៍ទោ **សម ដារ៉ា** អត្តលេខ ៣១៤១១

២៤- វរសេនីយ៍ទោ **ស្វាយ សារឿន** អត្តលេខ ៣៣៨៧៣

២៥- វរសេនីយ៍ទោ **ហោ ម៉ុនហួរ** អត្តលេខ ៥១០១៧

២៦- វរសេនីយ៍ទោ **ម៉េត ចាន់ដាឧុធ** អត្តលេខ ៥៦៩២៨

២៧- វរសេនីយ៍ទោ **តេង ច័ន្ទធីឡាពៅរ៍** អត្តលេខ ៥៧២៦០

២៨- វរសេនីយ៍ទោ **យឹម សំអាន** អត្តលេខ ៥៧៨៥១

២៩- វរសេនីយ៍ទោ **ចាន់ រឿន** អត្តលេខ ៦៤២៦៩

៣០- វរសេនីយ៍ទោ **ប៉ែន ណារិទ្ធ** អត្តលេខ ៦៧៩១០

៣១- វរសេនីយ៍ទោ **សុខ សំណាង** អត្តលេខ ៧១៩៤៨

៣២- វរសេនីយ៍ទោ **ជា ម៉ុនឌីបុល** អត្តលេខ ៧៩៨០០

៣៣- វរសេនីយ៍ទោ **ហ៊ឹម ជាវហេង** អត្តលេខ ៧៩៨០១

៣៤- វរសេនីយ៍ទោ **ជា សែនវិស្សុត** អត្តលេខ ៧៩៨០២ ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ថ្ងៃ ពុធ ១៥ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦២២ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរ និងតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១** ៖ ផ្ទេរ និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **សាន ម៉ុនធា** អត្តលេខ ០៦៧៣០ ពីអនុប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោក ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន ។

**មាត្រា ២** ៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១៥ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦២៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំង លោក **ផាន់ ចន្ទតារា** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការសាសនា នៅក្រសួងធម្មការ និងសាសនា។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១៥ កើត ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៦២៨.អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណ:រដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.**_បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនលោកសាស្ត្រាចារ្យ លោកវេជ្ជបណ្ឌិត ចំនួន ៤៤ រូប ដែលមានស្នាដៃល្អ ក្នុងការបង្ហាត់បង្រៀន ដល់សិស្ស និស្សិត នៃវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល កងយោធពលខេមរភូមិន្ទ កន្លងមក ដូចមានរាយនាមខាងក្រោម៖

**ក. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ១-លោក | **ជុំ** | **ណារុធ** | សាស្ត្រាចារ្យមហាបរិញ្ញា មន្ទីរពេទ្យមិត្តភាព ខ្មែរ សូវៀត |
| ២-លោក | **ស៊ិន** | **សាគ្គតា** | សាស្ត្រាចារ្យមហាបរិញ្ញា មន្ទីរពេទ្យ ព្រះកុសុម: |
| ៣-លោក | **លឹម** | **តាំង** | សាស្ត្រាចារ្យរង មន្ទីរពេទ្យ ព្រះកុសុម: |
| ៤-លោក | **រ៉ិច** | **ឃុយ** | វេជ្ជបណ្ឌិត មន្ទីរពេទ្យ ព្រះកុសុម: |
| ៥-លោក | **អាំង** | **អេងសុភាព** | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ៦-លោក | **ហ៊ាង** | **គង** | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ៧-លោក | **គីម** | **អាង** | សាស្ត្រាចារ្យមហាបរិញ្ញា មន្ទីរពេទ្យកុមារជាតិ |
| ៨-លោក | **ជា** | **ឌីរ៉ាជា** | សាស្ត្រាចារ្យរង មន្ទីរពេទ្យកុមារជាតិ |

**ខ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **អ៊ុំ** | **សាម៉ុល** | សាស្ត្រាចារ្យមហាបរិញ្ញា អនុរដ្ឋលេខាធិការ ក្រសួង សុខាភិបាល |
| ២-លោក | **ជា** | **គីមឡុង** | សាស្ត្រាចារ្យជំនួយ សាកលវិទ្យាល័យវិទ្យាសាស្ត្រ សុខាភិបាល |
| ៣-លោក | **ម៉ម** | **នន្ទ** | សាស្ត្រាចារ្យរង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |

| | | |
|---|---|---|
| ៤-លោក | សែម មន្នី | សាស្ត្រាចារ្យរង មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ៥-លោក | ផៃ ណារិទ្ធ | វេជ្ជបណ្ឌិត មន្ទីរពេទ្យកុមារជាតិ |
| ៦-លោក | ថាន់ ថាណាសិទ្ធិ | សាស្ត្រាចារ្យរង សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៧-លោក | ភាច ពិសិដ្ឋ | សាស្ត្រាចារ្យជំនួយ សាកលវិទ្យាល័យវិទ្យាសាស្ត្រ សុខាភិបាល |
| ៨-លោក | ប៊ិច ចំណាន | ឱសថការី រោងចក្រផលិតឱសថ ជា ចំណាន ព្រែកលាភ |
| ៩-លោក | គង់ ពិសិដ្ឋ | សាស្ត្រាចារ្យរង មន្ទីរពេទ្យព្រះអង្គឌួង |
| ១០-លោក | ជ្រិន ឆាមសុខ | សាស្ត្រាចារ្យ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ១១-លោក | ទន ទុន្តា | សាស្ត្រាចារ្យមហាបរិញ្ញា ព្រឹទ្ធបុរសរង មហាវិទ្យាល័យ ទន្តវេទនសាស្ត្រ |
| ១២-លោក | យ៉ែម សុផល | សាស្ត្រាចារ្យរង ប្រធានការិយាល័យសិក្សា មហាវិទ្យាល័យ ទន្តវេទនសាស្ត្រ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ១៣-លោក | សុខ លី | ទន្តបណ្ឌិត មន្ត្រីការិយាល័យស្រាវជ្រាវ មហាវិទ្យាល័យ ទន្តវេទនសាស្ត្រ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |

គ. មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ

| | | |
|---|---|---|
| ១-លោក | ហង្ស សុមេធ | សាស្ត្រាចារ្យមហាបរិញ្ញា អនុប្រធាន ការិយាល័យ ស្រាវជ្រាវ មហាវិទ្យាល័យទន្តវេទនសាស្ត្រ |
| ២-លោក | អែម សុធា | វេជ្ជបណ្ឌិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៣-លោក | ពេជ្រ សោភ័ណ្ឌ | វេជ្ជបណ្ឌិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៤-លោកស្រី | ម៉ី វណ្ណារ៉េត | វេជ្ជបណ្ឌិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៥-លោក | ស៊ុន ស៊ីដារ៉ុង | អនុបណ្ឌិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៦-លោក | ប៉ែន លីដា | អនុបណ្ឌិត សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ៧-លោក | រិត ច័ន្ទ | សាស្ត្រាចារ្យជំនួយ មន្ទីរពេទ្យ កុមារជាតិ |
| ៨-លោក | ឃាង បូមិត្ត | ឱសថបណ្ឌិត មជ្ឈមណ្ឌលជាតិផ្តល់ឈាម |
| ៩-លោក | គ្រុយ ស៊ុនឡាយ | សាស្ត្រាចារ្យ វិទ្យាស្ថានស្រាវជ្រាវជាតិប៉ាស្ទ័រ |
| ១០-លោក | ម៉ី ចាន់ណា | វេជ្ជបណ្ឌិត វិទ្យាស្ថានស្រាវជ្រាវជាតិប៉ាស្ទ័រ |
| ១១-លោក | ឆាយ គីមឆ៉ាង | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ១២-លោក | នី ថារួម | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ១៣-លោក | សុខ ស៊ីច័ន្ទ | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ១៤-លោក | អែម សាធឿន | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ១៥-លោក | ម៉ម ចាន់ដារ៉ា | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យកាល់ម៉ែត្រ |
| ១៦-លោក | ឆៀម ធីតា | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យមិត្តភាពខ្មែរ សូវៀត |
| ១៧-លោក | ហួ ឌី | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យព្រះកុសុមៈ |
| ១៨-លោកស្រី | អ៊ុន ចិន្តា | ឆ្មបមធ្យម មន្ត្រីនាយកដ្ឋានធនធានមនុស្ស ក្រសួងសុខាភិបាល |
| ១៩-លោក | ចាន់ សុភ័ស្ត | វេជ្ជបណ្ឌិតឯកទេស មន្ទីរពេទ្យព្រះកុសុមៈ |
| ២០-លោក | មុយ សាយ | ទន្តបណ្ឌិត មហាវិទ្យាល័យទន្តវេទនសាស្ត្រ |

២១- លោក ឡឹក ទិសិដ្ឋ ទន្តបណ្ឌិត មន្ត្រីទន្តវេទនសាស្ត្រ មន្ទីរពេទ្យ ព្រះកុសុមៈ

២២- លោក ប៉ុក បូរិន្ទ ទន្តបណ្ឌិត ប្រធានការិយាល័យស្រុក ប្រតិបត្តិ បាសាក់

២៣- លោកស្រី សាឯម ថាវរី វេជ្ជបណ្ឌិត មន្ទីរពេទ្យកាល់ម៉ែត្រ

**មាត្រា២.**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១៥ កើត ខែបឋមាសាឍ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ០១ សណន

# សេចក្ដីណែនាំ
# ស្ដីពី
# ការផ្អាកលក់ដូរ និងពិសាគ្រឿងស្រវឹងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨

កន្លងទៅ រាជរដ្ឋាភិបាលបានសង្កេតឃើញថា ការពិសាគ្រឿងស្រវឹងគ្រប់ប្រភេទ ភាគច្រើនអាចបង្កឱ្យមានអំពើហិង្សា គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម ការប្រព្រឹត្តបទល្មើសនានា ឬករណីខ្លះអាចបណ្ដាលឱ្យបាត់សណ្ដាប់ធ្នាប់សាធារណៈថែមទៀតផង។ អនុលោមតាមច្បាប់ បទបញ្ញា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងដើម្បីឱ្យដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ដែលព្រះរាជាណាចក្រកម្ពុជាខ្លួនឯងបានកំណត់រៀបចំធ្វើនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ គ្មានអំពើហិង្សា គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ និងបាតុភាពនានា ដែលអាចកើតមានឡើង ដោយសារតែការពិសាគ្រឿងស្រវឹងនោះ **រាជរដ្ឋាភិបាល** សូមធ្វើការណែនាំដូចខាងក្រោម :

១-ប្រជាពលរដ្ឋខ្មែរ និងជនបរទេសទាំងអស់ ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរួមសហការជាមួយរាជរដ្ឋាភិបាល កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ពាណិជ្ជករ និងអាជីវករ ដោយត្រូវផ្អាកការលក់ដូរ និងពិសាគ្រឿងស្រវឹងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ចាប់ពីថ្ងៃទី២៨ ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ដើម្បីរួមចំណែកទប់ស្កាត់អំពើហិង្សា ការគំរាមកំហែង ការបំភិតបំភ័យ គ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់សង្គម និងបាតុភាពនានា ដែលអាចបណ្ដាលមកពីការពិសាគ្រឿងស្រវឹងគ្រប់ប្រភេទ។

២-ក្រសួង ស្ថាប័ន កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ រួមជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការបំពាក់បំប៉នដល់មន្ត្រីរាជការក្រោមឱវាទ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងផ្សព្វផ្សាយ អប់រំណែនាំប្រជាពលរដ្ឋខ្មែរ និងជនបរទេសទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន អនុវត្តការផ្អាកការលក់ដូរ និងពិសាគ្រឿងស្រវឹង ក្នុងគោលបំណងធ្វើឱ្យកិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

នីតិកាលទី៦ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ ខាងមុខនេះ ប្រព្រឹត្តទៅក្នុងបរិយាកាសនយោបាយល្អ សេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា។

៣-រដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវសហការជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការផ្សព្វផ្សាយសេចក្តីណែនាំនេះ តាមគ្រប់ប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ជូនដល់ប្រជាពលរដ្ឋខ្មែរ ជនបរទេស ពាណិជ្ជករ អាជីវករ មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ឱ្យបានយល់ជ្រួតជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាព។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ត្រូវផ្សព្វផ្សាយអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃសុក្រ ᧷ ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល :</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់រដ្ឋបាលរាជធានី ខេត្ត
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ [illegible] សហវ.[illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០[illegible] ខែ[illegible] ឆ្នាំ២០១៨

# ប្រកាស

## ស្តីពី

## ការកែសម្រួលការប្រព្រឹត្តទៅ នៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- យោងប្រកាសលេខ ១៥០០ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ តម្លើងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនិងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកទេសវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញប្រកាស ១៤២៨ សហវ.នរក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីបង្កើតអង្គភាព ភាពជាដៃគូរវាងរដ្ឋនិងឯកជនថ្នាក់កណ្តាល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងកែសម្រួលការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម ÷

- រៀបចំបេសកកម្មនិងកែសម្រួលរចនាសម្ព័ន្ធរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រៀបចំមុខងារនិងភារកិច្ចរបស់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារ ក្នុងវិស័យថវិកា។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់នាយកដ្ឋាននិងអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## អំពីបេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤.-**

អគ្គនាយកដ្ឋានថវិកាបំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មគ្រប់គ្រងថវិកាជាតិ ក្នុងគោលដៅធានាឱ្យមានការបែងចែក និងប្រើប្រាស់ធនធានថវិការដ្ឋ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។

**ប្រការ៥.-**

អគ្គនាយកដ្ឋានថវិកាមានភារកិច្ចដូចតទៅ ÷

- កសាងសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ និងបទបញ្ញាហិរញ្ញវត្ថុសាធារណៈ
- រៀបចំការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ហិរញ្ញវត្ថុ បទបញ្ញាហិរញ្ញវត្ថុសាធារណៈ និងច្បាប់ដែលមានការពាក់ព័ន្ធផ្សេងទៀត
- ចូលរួមក្នុងការងារកសាងសេចក្តីព្រាងច្បាប់ទូទាត់ថវិកា

- រៀបចំកម្មវិធីចំណាយសាធារណៈទៀងទាត់ ដោយផ្អែកលើកម្មវិធីចំណូលសាធារណៈ ដែលត្រូវបានរៀបចំដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់ដំណើរការជាប្រចាំ និងសម្រាប់គម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន ដោយផ្អែកលើច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់កែតម្រូវ លិខិតបទដ្ឋានពាក់ព័ន្ធ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ ដែលបានទទួលការអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើការអនុវត្តចំណាយថវិការបស់រដ្ឋបាលថ្នាក់ជាតិ
- រៀបចំអាទិភាពវិនិយោគប្រចាំឆ្នាំ សម្រាប់គោលបំណងថវិកានីយកម្មលើគម្រោងវិនិយោគសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

**ប្រការ៦.-**

អគ្គនាយកដ្ឋានថវិកា មាននាយកដ្ឋានក្រោមឱវាទចំនួន ៤ ដូចខាងក្រោម ÷

១. នាយកដ្ឋានកិច្ចការទូទៅ

២. នាយកដ្ឋានថវិកានីយកម្ម

៣. នាយកដ្ឋានហិរញ្ញកិច្ច

៤. នាយកដ្ឋានវិនិយោគ។

**ប្រការ៧.-**

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួនជាជំនួយការ។

អង្គការលេខរបស់អគ្គនាយកដ្ឋានថវិកា ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

## ជំពូកទី៣

## នាយកដ្ឋានកិច្ចការទូទៅ

**ប្រការ៨.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារគ្រប់គ្រងកិច្ចការទូទៅ ដោយ មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់អគ្គនាយកដ្ឋាន
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមផ្សេងៗរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារពិធីការ និងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- ដឹកនាំការលើកគម្រោងថវិកានិងទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន នៅពេលអគ្គនាយកដ្ឋានក្លាយជាអង្គភាពថវិកា
- គ្រប់គ្រងមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យារបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងរៀបចំកម្មវិធីប្រជុំទៀងទាត់ និងរៀបចំរបាយការណ៍នៃកិច្ចប្រជុំរបស់អគ្គនាយកដ្ឋាន

- រៀបចំ គ្រប់គ្រង និងថែរក្សាប្រព័ន្ធព័ត៌មានវិទ្យារបស់អគ្គនាយកដ្ឋាន
- រៀបចំនិងគ្រប់គ្រងគេហទំព័ររបស់អគ្គនាយកដ្ឋាន
- សម្របសម្រួលនិងបូកសរុបលទ្ធផលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន។

**ប្រការ៩.-**

នាយកដ្ឋានកិច្ចការទូទៅ មានការិយាល័យក្រោមឱវាទចំនួន ២ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងបុគ្គលិក

២. ការិយាល័យព័ត៌មានវិទ្យានិងសរុប។

**ប្រការ១០.-**

ការិយាល័យរដ្ឋបាលនិងបុគ្គលិកមានភារកិច្ចដូចតទៅ÷

- ជាច្រកចេញ-ចូលសម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់អគ្គនាយកដ្ឋាន
- រៀបចំលិខិតស្នាមរដ្ឋបាលនិងបោះពុម្ពឯកសារផ្សេងៗ
- ទទួលបន្ទុកការងារពិធីការនិងទំនាក់ទំនងសាធារណៈរបស់អគ្គនាយកដ្ឋាន
- រៀបចំគម្រោងស្នើសុំថវិការបស់អគ្គនាយកដ្ឋាន នៅពេលអគ្គនាយកដ្ឋានក្លាយជាអង្គភាពថវិកា
- គ្រប់គ្រងនិងបែងចែកសម្ភារៈប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗរបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកការងារគណនេយ្យរបស់អគ្គនាយកដ្ឋាន នៅពេលអគ្គនាយកដ្ឋានក្លាយជាអង្គភាពថវិកា
- គ្រប់គ្រងមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន រាប់បញ្ចូលទាំងការគ្រប់គ្រងស្ថិតិ ការលើកយោបល់លើការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការរៀបចំប្រាក់បៀវត្សរ៍ និងការគាំពារផ្សេងៗ
- គ្រប់គ្រងវត្តមានមន្ត្រីរាជការរបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងស្ថិតិបុគ្គលិកជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែតរបស់អគ្គនាយកដ្ឋាន
- រៀបចំនិងសម្របសម្រួលកម្មវិធីបណ្តុះបណ្តាលផ្សេងៗរបស់អគ្គនាយកដ្ឋាន។

**ប្រការ១១.-**

ការិយាល័យព័ត៌មានវិទ្យានិងសរុបមានភារកិច្ច ដូចតទៅ÷

- ផ្តល់ការគាំទ្រខាងបច្ចេកទេសព័ត៌មានវិទ្យាដល់នាយកដ្ឋាននានាចំណុះអគ្គនាយកដ្ឋានថវិកា
- រៀបចំនិងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងការរៀបចំ ការដំឡើង និងការថែរក្សាប្រព័ន្ធបណ្តាញ និងការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែត នៅក្នុងអគ្គនាយកដ្ឋាន
- រៀបចំនិងបញ្ចូលទិន្នន័យផ្សេងៗ ពាក់ព័ន្ធនឹងចំណាយថវិកាចូលទៅប្រព័ន្ធបណ្តាញ
- បូកសរុបលទ្ធផលការងារ និងរៀបចំរបាយការណ៍ការងារទៀងទាត់របស់អគ្គនាយកដ្ឋាន
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋាន។

## ជំពូកទី៤
## នាយកដ្ឋានថវិកានីយកម្ម

**ប្រការ១២.-**

នាយកដ្ឋានថវិកានីយកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារថវិកានីយកម្ម ដោយមានភារកិច្ចដូចតទៅ÷

- ដឹកនាំនិងសម្របសម្រួលកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ រួមទាំងការរៀបចំសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងសារាចរស្តីពីការរៀបចំថវិកា សម្រាប់ឆ្នាំនីមួយៗ

- រៀបចំកញ្ចប់តួរលេខចំណូល និងចំណាយដំបូងរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត
- កសាងសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗ ច្បាប់កែតម្រូវ និងបទបញ្ញានានា
- ចូលរួមរៀបចំគោលនយោបាយចំណាយថវិកា ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- ចូលរួមក្នុងដំណើរការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្នុងការកសាងតារាងប្រតិបត្តិការហិរញ្ញវត្ថុប្រចាំខែ
- ចូលរួមរៀបចំគម្រោងក្របខណ្ឌចំណាយរយៈពេលមធ្យម
- ដឹកនាំការរៀបចំកម្មវិធីចំណូល និងចំណាយប្រចាំត្រីមាសរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ដើម្បីអនុវត្ត
- ដឹកនាំធ្វើការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំចលនាឥណទាន និងសំណើសុំបន្ថែមឥណទានរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំប្រើឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល
- បូកសរុបការអនុវត្តនិងប៉ាន់ស្មានការអនុវត្តថវិកាប្រចាំឆ្នាំ
- ចូលរួមផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត។

**ប្រការ១៣.-**

នាយកដ្ឋានថវិកានីយកម្ម មានការិយាល័យក្រោមឱវាទចំនួន ៧ ដូចខាងក្រោម ÷

១. ការិយាល័យរដ្ឋបាលនិងសរុបថវិកា

២. ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ

៣. ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៤. ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១

៥. ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២

៦. ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១

៧. ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២។

**ប្រការ១៤.-**

ការិយាល័យរដ្ឋបាលនិងសរុបថវិកា មានតួនាទីនិងភារកិច្ចដូចតទៅ ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ-ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- សម្របសម្រួលគ្រប់ការិយាល័យចំណុះនាយកដ្ឋានពាក់ព័ន្ធនឹងការងាររៀបចំថវិកា តាមដានការអនុវត្តថវិកា និងប្រមូលផ្តុំទិន្នន័យចំណូលនិងចំណាយថវិកា
- សម្របសម្រួលកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សម្របសម្រួលការរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស សម្រាប់ការអនុវត្តថវិកា
- ដឹកនាំធ្វើការត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំចលនាឥណទាន និងសំណើសុំបន្ថែមឥណទានរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញរាជធានី ខេត្ត
- ពិនិត្យនិងផ្តល់មតិជូនថ្នាក់ដឹកនាំក្រសួង លើសំណើសុំប្រើឥណទានថវិកាមិនទាន់បែងចែករបស់រាជរដ្ឋាភិបាល

- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ១៥.-**

ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ក្រសួងព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការ-បរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ អង្គភាពប្រឆាំងអំពើពុករលួយ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ១៦.-**

ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ប្រការ១៧.-**

ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញ ខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងធម្មការនិងសាសនា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ១៨.-**

ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញ ខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។

**ប្រការ១៩.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងធនធានទឹកនិងឧតុនិយម។

**ប្រការ២០.-**

ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រួមទាំងមន្ទីរជំនាញខ្សែបណ្តោយរាជធានី ខេត្ត ដែលរួមមាន÷ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងទេសចរណ៍។

**ប្រការ២១.-**

ការិយាល័យថវិកាវិស័យរដ្ឋបាលទូទៅ ការិយាល័យថវិកាវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការិយាល័យថវិកាវិស័យសង្គមកិច្ចទី១ ការិយាល័យថវិកាវិស័យសង្គមកិច្ចទី២ ការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី១និងការិយាល័យថវិកាវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ច ដូចតទៅ÷

- រៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្តាយរាជធានី ខេត្ត
- សហការក្នុងកិច្ចដំណើរការបច្ចេកទេស ដើម្បីរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- សហការរៀបចំសារាចរស្តីពីការកសាងគម្រោងចំណូលនិងចំណាយថវិការដ្ឋប្រចាំឆ្នាំនីមួយៗ

- រៀបចំតួលេខត្រួតពិនិត្យចំណូល-ចំណាយថវិកាឱ្យក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្ដោយ រាជធានី ខេត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ និងដើម្បីអនុវត្ត
- សហការជាមួយមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំកសាងផែនការថវិកាប្រចាំឆ្នាំរបស់មន្ទីរជំនាញខ្សែបណ្ដោយ រាជធានី ខេត្ត
- សហការក្នុងដំណើរការរៀបចំសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ
- កត់ត្រា តាមដានជាប្រចាំនិងទៀងទាត់ លើការអនុវត្តថវិការបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្ដោយ រាជធានី ខេត្ត
- ពិនិត្យនិងផ្ដល់យោបល់ លើសំណើចលនាឥណទាន និងសំណើសុំឥណទានបន្ថែមរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញខ្សែបណ្ដោយរាជធានី ខេត្ត
- បូកសរុបសភាពការណ៍អនុវត្តថវិកា ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- ចូលរួមផ្ដល់យោបល់លើសេចក្ដីព្រាងច្បាប់ទូទាត់ថវិកាជាតិប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញ រាជធានី ខេត្ត។

## ជំពូកទី៥
## នាយកដ្ឋានហិរញ្ញកិច្ច

**ប្រការ២២.-**

នាយកដ្ឋានហិរញ្ញកិច្ច បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារហិរញ្ញកិច្ច ដោយមានភារកិច្ចដូចតទៅ ÷

- អនុវត្តការងារត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈរដ្ឋបាល
- អនុវត្តការងារពាក់ព័ន្ធបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- គ្រប់គ្រងសកម្មភាព សម្របសម្រួល និងតាមដានការអនុវត្តរបស់អភិបាលហិរញ្ញវត្ថុ
- កត់ត្រាជាប្រចាំ និងបូកសរុបទៀងទាត់ នូវកិច្ចសន្យាចំណាយ
- ពិនិត្យនិងផ្ដល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើសំណើសុំចំណាយថវិការបស់ក្រសួង ស្ថាប័ន
- ត្រួតពិនិត្យការអនុវត្តចំណាយថវិការបស់ក្រសួង ស្ថាប័ន
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខារ សេវា និងសំណង់
- ពិនិត្យនិងផ្ដល់យោបល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើគ្រប់សំណើសុំបុរេប្រទានថវិការបស់ក្រសួង ស្ថាប័ន ចំណាយតាមការចាំបាច់ជាក់ស្ដែង
- ផ្ដល់ទិដ្ឋាការលើអាណត្តិបើកប្រាក់
- ផ្ដល់យោបល់បច្ចេកទេសដល់អាណាប័ក ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ
- ផ្ដល់កិច្ចសហការក្នុងការរៀបចំថវិកា និងច្បាប់ហិរញ្ញវត្ថុ។

**ប្រការ២៣.-**

នាយកដ្ឋានហិរញ្ញកិច្ច មានការិយាល័យក្រោមឱវាទចំនួន ៧ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ

៣. ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ

៤. ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១

៥. ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២

៦. ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១

៧. ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២។

**ប្រការ២៤.-**

ការិយាល័យរដ្ឋបាលនិងសរុប មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន
- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួលនិងប្រមូលផ្តុំទិន្នន័យ ពាក់ព័ន្ធនឹងការងារអនុវត្តថវិកា
- ទទួលបន្ទុកធ្វើសំយោគរបាយការណ៍ទាំងអស់ ដែលទទួលបានពីគ្រប់ការិយាល័យគ្រប់គ្រងហិរញ្ញកិច្ច ស្តីពីការអនុវត្តថវិការដ្ឋ ដែលមានជាអាទិ៍ របាយការណ៍ធានាចំណាយ និងរបាយការណ៍ចេញអាណត្តិបើកប្រាក់
- សម្របសម្រួលការកសាងនីតិវិធី និងបទដ្ឋានចំណាយផ្សេងៗ សម្រាប់អនុវត្តជាទូទៅ
- ចូលរួមរៀបចំកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស សម្រាប់ការអនុវត្តថវិកា
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ២៥.-**

ការិយាល័យគ្រប់គ្រងហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ក្រសួងព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ២៦.-**

ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ តុលាការកំពូល សាលាឧទ្ធរណ៍ និងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

**ប្រការ២៧.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន ÷ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងធម្មការនិងសាសនា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ២៨.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី។

**ប្រការ២៩.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងធនធានទឹកនិងឧតុនិយម។

**ប្រការ៣០.-**

ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន ដែលរួមមាន÷រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងទេសចរណ៍។

**ប្រការ៣១.-**

ការិយាល័យហិរញ្ញកិច្ចវិស័យរដ្ឋបាលទូទៅ ការិយាល័យហិរញ្ញកិច្ចវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី១ ការិយាល័យហិរញ្ញកិច្ចវិស័យសង្គមកិច្ចទី២ ការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី១ និងការិយាល័យហិរញ្ញកិច្ចវិស័យសេដ្ឋកិច្ចទី២ ទទួលបន្ទុកការងារពាក់ព័ន្ធក្រសួង ស្ថាប័ន រៀងៗខ្លួនដោយមានភារកិច្ចដូចតទៅ ÷

- តាមដាននិងសម្របសម្រួលសកម្មភាពអនុវត្តរបស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ
- ប្រមូលផ្តុំព័ត៌មាន និងទិន្នន័យនៃសន្យាចំណាយ ការប្រើប្រាស់ឥណទាន និងការបញ្ចេញអាណត្តិ
- ធ្វើសំយោគរបាយការណ៍របស់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ស្តីពីការអនុវត្តចំណាយថវិការដ្ឋ ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ និងការប្រតិបត្តិនៃកិច្ចសន្យាគម្រោង ដើម្បីលើកយោបល់អំពីវិធានការចាំបាច់ដែលត្រូវធ្វើការកែលម្អកែទម្រង់ សំដៅលុបបំបាត់កង្វះខាតទាំងឡាយ ដែលកត់សម្គាល់ឃើញជាយថាហេតុ
- ចូលរួមក្នុងការរៀបចំកម្មវិធីចំណូល ចំណាយសាធារណៈប្រចាំខែ ត្រីមាស និងអនុវត្តកម្មវិធីនេះ ឱ្យបានខ្ជាប់ខ្ជួន
- ចូលរួម និងសិក្សាអំពីតម្រូវការចំណាយនានារបស់ក្រសួង ស្ថាប័ន សម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំនីមួយៗ និងសម្រាប់ការរៀបចំកម្មវិធីចំណាយរយៈពេលមធ្យម
- ពិនិត្យនិងផ្តល់យោបល់លើសំណើសុំបុរេប្រទានថវិការបស់ក្រសួង ស្ថាប័នចំណាយ។

**ប្រការ៣២.-**

នាយកដ្ឋានហិរញ្ញកិច្ច មានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នៅអមក្រសួង ស្ថាប័ននីមួយៗ ដែលអាចមានចំនួនមួយរូប ឬច្រើនរូប។

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដឹកនាំដោយប្រធានមួយរូប មានឋានៈស្មើប្រធានការិយាល័យ ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ ឋានៈស្មើអនុប្រធានការិយាល័យ។

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៣៣.-**

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមក្រសួង ស្ថាប័ន មានភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យហិរញ្ញវត្ថុនៃការអនុវត្តចំណាយរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងប្រសិទ្ធភាព ភាពចាំបាច់ និងភាពត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីហិរញ្ញវត្ថុ
- ពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង ក្នុងការផ្តល់ទិដ្ឋាការលើអាណត្តិបើកប្រាក់
- ផ្តល់ប្រឹក្សាជាប្រចាំ អំពីនីតិវិធីចំណាយ ចំពោះផ្នែកនានារបស់អាណាប័ក
- ពិនិត្យនិងផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួង លើរាល់សំណើសុំថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលចំណុះក្រសួង ស្ថាប័ន

- ត្រួតពិនិត្យប្រតិបត្តិការហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខារ សេវា និងសំណង់
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន
- កាន់កាប់បញ្ជីគណនេយ្យសន្យាចំណាយ និងអាណត្តិកិច្ចតាមលក្ខខណ្ឌ ដូចខាងក្រោម÷
  - គណនេយ្យចំណាយវលញ្ជិក សម្រាប់ចំណាយចុះកិច្ចសន្យា
  - គណនេយ្យចំណាយអាណាប័ណ្ណ សម្រាប់អាណត្តិបើកប្រាក់។

## ជំពូកទី៦
## នាយកដ្ឋានវិនិយោគ

**ប្រការ៣៤.-**

នាយកដ្ឋានវិនិយោគ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានថវិកា លើការងារវិនិយោគ ដោយមានភារកិច្ចដូចតទៅ ÷

- ចូលរួមរៀបចំគោលនយោបាយចំណាយវិនិយោគសាធារណៈ និងចំណាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- គ្រប់គ្រងឥណទានថវិកាគម្រោងវិនិយោគផ្ទាល់ និងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការចំណាយវិនិយោគសាធារណៈ និងផែនការចំណាយ ថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយ
- ត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយវិនិយោគសាធារណៈ និងចំណាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យនិងវាយតម្លៃលទ្ធផលការងាររបស់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនីមួយៗ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលសម្ភារៈ បរិក្ខា សេវា និងសំណង់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យ និង វាយតម្លៃលទ្ធផលការងាររបស់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនីមួយៗ
- ចូលរួមក្នុងដំណើរការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ចូលរួមរៀបចំ តាមដាន និងត្រួតពិនិត្យលើការអនុវត្តគម្រោង ឬកិច្ចព្រមព្រៀង ឬកិច្ចសន្យាពាក់ព័ន្ធនឹងការវិនិយោគឯកជន ដែលមានពាក់ព័ន្ធនឹងចំណាយថវិការដ្ឋ ឬដែលមានពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលរបស់រដ្ឋ។

**ប្រការ៣៥.-**

នាយកដ្ឋានវិនិយោគមានការិយាល័យក្រោមឱវាទចំនួន ៥ ដូចខាងក្រោម÷

១. ការិយាល័យរដ្ឋបាលនិងសរុប

២. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១

៣. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២

៤. ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣

៥. ការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ។

**ប្រការ៣៦.-**

ការិយាល័យរដ្ឋបាលនិងសរុប មានតួនាទីនិងភារកិច្ចដូចតទៅ÷

- ជាលេខាធិការដ្ឋានរបស់ប្រធាននាយកដ្ឋាន

- ជាច្រកចេញ ចូល សម្រាប់ឯកសារពាក់ព័ន្ធនឹងការងាររបស់នាយកដ្ឋាន
- ជាកន្លែងតម្កល់ឯកសារ និងលិខិតស្នាមផ្សេងៗរបស់នាយកដ្ឋាន
- រៀបចំសំណើកម្មវិធីបណ្ដុះបណ្ដាល និងអភិវឌ្ឍធនធានមនុស្សរបស់នាយកដ្ឋាន
- ជាចំណុចសម្របសម្រួលនិងប្រមូលផ្ដុំទិន្នន័យពាក់ព័ន្ធនឹងការងារអនុវត្តថវិកា
- ទទួលបន្ទុកធ្វើសំយោគរបាយការណ៍ទាំងអស់ ដែលទទួលបានពីគ្រប់ការិយាល័យជំនាញ ស្ដីពីការអនុវត្តថវិការដ្ឋ ដែលមានជាអាទិ៍របាយការណ៍ធានាចំណាយ និងរបាយការណ៍ចេញអាណត្តិបើកប្រាក់
- គ្រប់គ្រងឥណទានថវិកាវិនិយោគផ្ទាល់ និងឥណទានថវិកាថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- បូកសរុបរបាយការណ៍ចំណាយ និងរបាយការណ៍ពាក់ព័ន្ធផ្សេងទៀតរបស់នាយកដ្ឋាន
- សម្របសម្រួលការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់នាយកដ្ឋាន។

**ប្រការ៣៧.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងព្រះបរមរាជវាំង រដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ ទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា ក្រសួងកិច្ចការនារី ក្រសួងយុត្តិធម៌ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងអង្គភាពប្រឆាំងអំពើពុករលួយ។

**ប្រការ៣៨.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងផែនការ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៣៩.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន ដែលរួមមាន ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងធនធានទឹក និងឧតុនិយម។

**ប្រការ៤០.-**

ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី១ ការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី២ និងការិយាល័យវិនិយោគសាធារណៈក្នុងស្រុកទី៣ ទទួលបន្ទុកការងារពាក់ព័ន្ធកិច្ចការវិនិយោគសាធារណៈក្នុងស្រុក នៃក្រសួង ស្ថាប័ន រៀងៗខ្លួន ដោយមានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយចំណាយវិនិយោគសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម ដោយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមជាមួយក្រសួង ស្ថាប័ន រៀបចំផែនការចំណាយវិនិយោគ សម្រាប់គោលបំណងថវិកានីយកម្ម
- អនុវត្តការផ្ដល់ហិរញ្ញប្បទានសម្រាប់គម្រោងវិនិយោគសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយ
- ត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយគម្រោងវិនិយោគសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលសម្ភារៈ បរិក្ខារ សេវា និងសំណង់
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន

- រៀបចំរបាយការណ៍ទៀងទាត់ នៃចំណាយគម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន។

**ប្រការ៤១.-**

ការិយាល័យថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មានភារកិច្ចដូចតទៅ÷

- រៀបចំគោលនយោបាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដូចជា ÷ ផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ ដោយត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ
- ចូលរួមរៀបចំផែនការចំណាយថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ សម្រាប់គោលបំណងថវិកានីយកម្ម
- អនុវត្តការផ្តល់ហិរញ្ញប្បទានសម្រាប់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដោយផ្អែកលើកម្មវិធីចំណាយដែលបានអនុម័តរួច
- ត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលសម្ភារៈ បរិក្ខា សេវា និងសំណង់
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យ និងវាយតម្លៃលទ្ធផលការងាររបស់គម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈនីមួយៗ
- ចូលរួមក្នុងដំណើរការរៀបចំថវិការបស់ក្រសួង ស្ថាប័ន
- រៀបចំរបាយការណ៍ទៀងទាត់ នៃចំណាយគម្រោងវិនិយោគសាធារណៈរបស់ក្រសួង ស្ថាប័ន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ៤២.-**

ក្នុងពេលបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬស្នើសុំពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ៤៣.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៤៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី១
នៃប្រកាសលេខ            សហវ.ប្រក
ចុះថ្ងៃទី      ខែ      ឆ្នាំ២០១៨
ស្តីពីការកែសម្រួលការរៀបចំ និងការ
ប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាព
ក្រោមឱវាទអគ្គនាយកដ្ឋានថវិកា
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## អង្គការលេខនៃអគ្គនាយកដ្ឋានថវិកា



**ឧបសម្ព័ន្ធទី២**

**នៃប្រកាសលេខ សហវ.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០១៨ ស្តីពីការ**

**កែសម្រួលការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាននិងអង្គភាពក្រោមឱវាទ**

**អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុមានដូចតទៅ÷

១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងព្រះបរមរាជវាំង
២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ព្រឹទ្ធសភា
៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋសភា
៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រុមប្រឹក្សាធម្មនុញ្ញ
៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម អាជ្ញាធរសវនកម្មជាតិ
៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ទីស្តីការគណៈរដ្ឋមន្ត្រី
៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមុខងារសាធារណៈ
៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
១០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងយុត្តិធម៌
១១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
១២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
១៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
១៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងផែនការ
១៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ
១៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការពារជាតិ
១៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងមហាផ្ទៃ ផ្នែករដ្ឋបាលទូទៅ
១៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
១៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងទេសចរណ៍
២០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
២១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
២២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអភិវឌ្ឍន៍ជនបទ
២៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងធនធានទឹក និងឧតុនិយម
២៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសាធារណការ និងដឹកជញ្ជូន
២៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
២៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងពាណិជ្ជកម្ម
២៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
២៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

២៩- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងព័ត៌មាន

៣០- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងបរិស្ថាន

៣១- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសុខាភិបាល

៣២- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងអប់រំ យុវជន និងកីឡា

៣៣- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

៣៤- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងធម្មការ និងសាសនា

៣៥- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងកិច្ចការនារី

៣៦- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

៣៧- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម អង្គភាពប្រឆាំងអំពើពុករលួយ

៣៨- ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអម ក្រសួងរ៉ែ និងថាមពល ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៤៩៧ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
# ស្តីពី
# តម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងនីតិវិធីអនុវត្តចំណាយ

| ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី | រដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
|---|---|---|
| ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | ក្រសួងសុខាភិបាល |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រពឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៣/០១២ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- បានឃើញប្រកាសអន្តរក្រសួងលេខ៤០៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ ២០១៧ ស្តីពីការអនុវត្តការថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន
- យោងតាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណង ÷

- សម្រួលនីតិវិធីនៃការអនុវត្តចំណាយថវិការបស់មូលនិធិសមធមិសុខាភិបាល ដើម្បីលើកកម្ពស់ការផ្តល់សេវាសុខាភិបាលប្រកបដោយគុណភាព សុវត្ថិភាព ប្រសិទ្ធភាព និងសមធមិ
- ពង្រឹង និងបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការគ្រប់គ្រងចំណាយថវិការបស់មូលនិធិសមធមិសុខាភិបាល និងថវិកាប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់÷

- តម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធមិសុខាភិបាល និងនីតិវិធីអនុវត្តចំណាយមូលនិធិសមធមិសុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ រួមមាន÷ មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព
- ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន និងនីតិវិធីអនុវត្តចំណាយថវិកាប្រាក់ឧបត្ថម្ភសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។

**ប្រការ ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះ÷

- ការប្រើប្រាស់សេវាព្យាបាលរបស់មូលនិធិសមធមិសុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ រួមមាន÷ មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព
- ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រី នៅពេលសម្រាលកូននៅមូលដ្ឋានសុខាភិបាល ដោយបេឡាជាតិរបបសន្តិសុខសង្គម (**ប.ស.ស.**)។

**ប្រការ ៤.-**

វាក្យស័ព្ទដែលប្រើក្នុងប្រកាសនេះ មានន័យ ដូចខាងក្រោម÷

**តម្លៃកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធមិសុខាភិបាល** សំដៅដល់តម្លៃនៃកញ្ចប់សេវាព្យាបាលនីមួយៗរបស់មូលដ្ឋានសុខាភិបាលសាធារណៈ ដែលត្រូវទូទាត់ដោយថវិការដ្ឋក្នុងក្របខ័ណ្ឌនៃឥណទានថវិការបស់ក្រសួងសុខាភិបាល ជូនអ្នកជំងឺក្រីក្រ កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល ដែលបានមក

ប្រើប្រាស់សេវាព្យាបាលតាមរយៈមូលនិធិសមធម៌សុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ដែលរួមមាន មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព ។

**មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព** សំដៅដល់មូលដ្ឋានសុខាភិបាលសាធារណៈជួរមុខ និងថ្នាក់ក្រោមបំផុត ដែលមានតួនាទីផ្តល់សេវាសុខភាពជាមូលដ្ឋាន ដល់ប្រជាជនរស់នៅក្នុងតំបន់ទទួលខុសត្រូវរបស់មណ្ឌលសុខភាព (ពី ៨.០០០ -១២.០០០នាក់)។ សេវាសុខភាពជាមូលដ្ឋាននោះ មានជាអាទិ៍ សេវាអប់រំនិងលើកកម្ពស់សុខភាព សេវាបង្ការជំងឺ និងព្យាបាលជាមូលដ្ឋាន តាមរយៈការផ្តល់សេវានៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពផ្ទាល់ ការចុះផ្តល់សេវាតាមមូលដ្ឋាន និងការបញ្ជូនទៅមន្ទីរពេទ្យបង្អែក។ មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពផ្តល់សេវាសំណុំសកម្មភាពអប្បបរមារួមមាន សេវាសុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ អាហារូបត្ថម្ភ សេវាជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈដទៃទៀត ។

**មន្ទីរពេទ្យបង្អែក** សំដៅដល់ថ្នាក់បង្អែករបស់មណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព និងមានតួនាទីផ្តល់សេវាពិគ្រោះជំងឺក្រៅ និងសេវាពិគ្រោះជំងឺក្រៅឯកទេស/ជំងឺបញ្ជូន និងសេវាសម្រាកព្យាបាល ចំពោះជំងឺ ឬ បញ្ហាសុខភាពណាដែលមានលក្ខណៈស្មុគ្រស្មាញ ដោយរាប់បញ្ចូលទាំងសេវាវះកាត់ ហើយដែលមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាពគ្មានសមត្ថភាពផ្តល់បាន ដូចជា សេវាឯកទេស ធ្វើរោគវិនិច្ឆ័យ ព្យាបាលថែទាំ និងស្តារនីតិសម្បទា។ មន្ទីរពេទ្យបង្អែកចែកចេញជាពាកម្រិតគឺ មន្ទីរពេទ្យបង្អែកកម្រិត១, កម្រិត២ ជាមន្ទីរពេទ្យបង្អែកស្រុក/ក្រុង/ខណ្ឌ និងមន្ទីរពេទ្យបង្អែកកម្រិត៣ ជាមន្ទីរពេទ្យបង្អែករាជធានី/ខេត្ត ។

**មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ** ជាបង្អែករបស់មន្ទីរពេទ្យបង្អែកស្រុក/ក្រុង/ខណ្ឌ/រាជធានី/ខេត្ត។ មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ ផ្តល់សេវាពិគ្រោះនិងព្យាបាល បណ្តុះបណ្តាលមូលដ្ឋាន និងបណ្តុះបណ្តាលបន្តផ្នែកគ្លីនិកនិងអមគ្លីនិក និងជាកន្លែងធ្វើកម្មសិក្សាអនុវត្តជាក់ស្តែងរបស់សិស្សនិស្សិតពេទ្យ ព្រមទាំងផ្តល់ការអភិបាលគាំទ្រផ្នែកបច្ចេកទេស និងគ្លីនិកដល់បុគ្គលិកមណ្ឌលសុខភាព។

# ជំពូកទី២

# កញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល និង ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

## ផ្នែកទី១

## កញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល

**ប្រការ ៥.-**

មូលដ្ឋានសុខាភិបាលសាធារណៈ អាចទូទាត់កញ្ចប់សេវាថែទាំសុខភាពតែមួយប៉ុណ្ណោះអំឡុងពេលទទួលសេវា១លើករបស់អ្នកជំងឺម្នាក់។ កញ្ចប់សេវាថែទាំសុខភាពខាងក្រោមរួមបញ្ចូលរាល់សេវាអមគ្លីនិកដែលចាំបាច់នានា ដើម្បីគាំទ្រដល់ការកំណត់រោគវិនិច្ឆ័យនៃជំងឺ។

កញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធម៌សុខាភិបាល រួមមាន÷ សេវាពិគ្រោះជំងឺក្រៅ សេវាពន្យារកំណើត សេវាសម្រាកព្យាបាលទូទៅ សេវាសង្គ្រោះបន្ទាន់ សេវាសម្រាកព្យាបាលវះកាត់តូច សេវាព្យាបាលវះកាត់ធំ និងសេវាសម្រាលកូនធម្មតា ដែលត្រូវបានកំណត់ដូចខាងក្រោម÷

**ក. កញ្ចប់តម្លៃសេវាថែទាំសុខភាពនៅមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព**

ឯកតា: រៀល

| ល.រ | ការផ្តល់សេវាថែទាំសុខភាព | មណ្ឌលសុខភាព/ ប៉ុស្តិ៍សុខភាព | មណ្ឌលសុខភាព មានគ្រែសម្រាកព្យាបាល (អតីតមន្ទីរពេទ្យស្រុក) |
|---|---|---|---|
| ១ | ពិគ្រោះជំងឺក្រៅ | ៤ ០០០ | ៤ ០០០ |
| | **ពិគ្រោះទូទៅ** នៃជំងឺ ឬ បញ្ហាសុខភាព របស់ប្រជាពលរដ្ឋគ្រប់វ័យ ទាក់ទងនឹងសុខភាពបន្តពូជ ជំងឺឆ្លង ជំងឺមិនឆ្លង និងបញ្ហាសុខភាពសាធារណៈផ្សេងៗ ដូចបានកំណត់នៅក្នុងសំណុំសកម្មភាពអតិបរមាសម្រាប់មណ្ឌលសុខភាព ។ | | |
| | **វិធីពន្យារកំណើតរយៈពេលវែង** ដោយដាក់កងក្នុងស្បូន ឬ កងនៅក្រោមស្បែក (IUD/Implant) | ២០ ០០០ | ២០ ០០០ |
| | **ពិនិត្យរកមហារីកមាត់ស្បូន÷** ស្រាវជ្រាវបឋមនៃបញ្ហាមហារីកមាត់ស្បូន និងផ្តល់ការព្យាបាលដោយ Cryotherapy។ ក្នុងករណីសង្ស័យមហារីកមាត់ស្បូន ត្រូវណែនាំ និងចេញលិខិតបញ្ជូនឱ្យអ្នកជំងឺទៅបន្តការពិនិត្យស្រាវជ្រាវ និងធ្វើរោគវិនិច្ឆ័យនៅមន្ទីរពេទ្យបង្អែក។ | ២០ ០០០ | ២០ ០០០ |

| | | | |
|---|---|---|---|
| ២ | **សង្គ្រោះបន្ទាន់ (ទោះត្រូវបញ្ជូន ឬ មិនបញ្ជូន)** | ២០ ០០០ | ២០ ០០០ |
| | ជាអន្តរាគមន៍សង្គ្រោះបឋមដល់អ្នកជំងឺ ឬ ជនរងគ្រោះដែលកំពុងប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិត ដោយសារសញ្ញាជីវិត (កំដៅខ្លួន ចង្វាក់ដីពចរ បេះដូង ចង្វាក់ដង្ហើម និងសម្ពាធឈាម) មានសភាពគ្រោះថ្នាក់ ដែលបណ្តាលមកពីជំងឺ ឬ ឧប្បត្តិហេតុគ្រោះថ្នាក់នានា មានជាអាទិ៍ សន្លប់បាត់បង់ស្មារតី ឈឺចុកចាប់របួសបាក់ឆ្អឹង លង់ទឹក ពស់ចឹក ពុល។ល។ ករណីសង្គ្រោះបន្ទាន់នេះរួមមាន÷ ពិនិត្យ តាមដាន និងកត់ត្រាសញ្ញាជីវិតជាប្រចាំ និងព្យាបាលដោយប្រើប្រាស់ឱសថ/បរិក្ខារ សេរ៉ូម អុកស៊ីហ្សែន និងមធ្យោបាយសង្គ្រោះចាំបាច់នានាយោងតាមលក្ខខណ្ឌវេជ្ជសាស្ត្រ ព្រមទាំងរៀបចំចាត់ចែងបញ្ជូនទៅមន្ទីរពេទ្យបង្អែក (ត្រូវចេញលិខិតបញ្ជូនភ្ជាប់ជាមួយឯកសារវេជ្ជសាស្ត្ររបស់អ្នកជំងឺ/ជនរងគ្រោះ) ក្នុងករណីចាំបាច់។ | | |
| ៣ | **សម្រាល និងរំលូត/រលូត** | ៨០ ០០០ | ៨០ ០០០ |
| | ករណីណាមួយនៃករណីខាងក្រោមនេះ ត្រូវបានទូទាត់តាម **តម្លៃសម្រាល និងរំលូត/រលូត÷**<br>• សម្រាលធម្មតា (ដោយមិនត្រូវការអន្តរាគមន៍បន្ថែម)<br>• សម្រាលប្រឈមនឹងគ្រោះថ្នាក់ ដែលត្រូវការអន្តរាគមន៍យោងទៅតាមពិធីសារ នៃការសម្រាលប្រឈមនឹងគ្រោះថ្នាក់ដែលអនុញ្ញាតឱ្យមណ្ឌលសុខភាពផ្តល់អន្តរាគមន៍បាន។<br>• **រំលូត/រលូត និងការថែទាំក្រោយរំលូត/រលូត:** មណ្ឌលសុខភាពត្រូវបានអនុញ្ញាតឱ្យផ្តល់សេវារំលូត/រលូត ក្នុងករណីដែលអាយុគភ៌ក្រោម ១២សប្តាហ៍។ ការថែទាំក្រោយរំលូត/រលូតរួមបញ្ចូលទាំងការផ្តល់ឱសថព្យាបាល/បរិក្ខារ និងមធ្យោបាយពន្យារកំណើត (បើចាំបាច់)។ | | |
| ៤ | **សម្រាកព្យាបាល** | × | ៨០ ០០០ |
| | - ចាត់ទុកថា គឺជាការព្យាបាលជា ១ (មួយ)ករណីសម្រាកព្យាបាល កាលណាអ្នកជំងឺម្នាក់ត្រូវបានវេជ្ជបណ្ឌិត/គ្រូពេទ្យ | | |

| | | | |
|---|---|---|---|
| | ដាក់ឱ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាព ចាប់ពី ២៤ ម៉ោងឡើង រហូតដល់ថ្ងៃដែលវេជ្ជបណ្ឌិត/គ្រូពេទ្យអនុញ្ញាតឱ្យអ្នកជំងឺនោះចេញពីមន្ទីរពេទ្យ ។ ករណីអ្នកជំងឺសម្រាកព្យាបាលតិចជាង ២៤ ម៉ោង ត្រូវចាត់ទុកថា ជាករណីពិគ្រោះជំងឺក្រៅ ។<br>- ករណីសម្រាកព្យាបាល រាប់បញ្ចូល ការពិនិត្យ ធ្វើរោគវិនិច្ឆ័យ (គិតទាំងរាល់សេវាអមគ្លីនិកដែលចាំបាច់នានា ដើម្បីគាំទ្រដល់ការកំណត់រោគវិនិច្ឆ័យនៃជំងឺ) ឱសថ/បរិក្ខារសម្រាប់ការព្យាបាល និងថែទាំ។ | | |

**ខ. តារាងតម្លៃសេវាថែទាំសុខភាពនៅមន្ទីរពេទ្យបង្អែក មន្ទីរពេទ្យជាតិ និងមជ្ឈមណ្ឌលជាតិ**

ឯកតា: រៀល

| ល.រ | សេវាសុខភាព | មន្ទីរពេទ្យបង្អែកកម្រិត ១ | មន្ទីរពេទ្យបង្អែកកម្រិត ២ | មន្ទីរពេទ្យបង្អែកកម្រិត ៣ | មន្ទីរពេទ្យជាតិ/មជ្ឈមណ្ឌលជាតិ |
|---|---|---|---|---|---|
| ១ | ពិគ្រោះពិនិត្យជំងឺក្រៅ (ក្នុងនោះរាប់បញ្ចូលករណីវះកាត់តូចតាចដែលសំដៅដល់ការដេរមុខរបួសលាងរបួស វះបូស.....) | ១០ ០០០ | ១៦ ០០០ | ៣២ ០០០ | ៤០ ០០០ |
| ២ | វិធីពន្យារកំណើតដោយដាក់កងក្នុងស្បូន ឬ នៅដើមដៃ | ២០ ០០០ | ២០ ០០០ | ២០ ០០០ | ២០ ០០០ |
| ៣ | វិធីបញ្ឈប់កំណើត (vasectomy and tubal ligation) | × | ១០០ ០០០ | ១០០ ០០០ | ១០០ ០០០ |
| ៤ | សម្រាកព្យាបាល | ៨០ ០០០ | ១០០ ០០០ | ១២០ ០០០ | ១៤០ ០០០ |
| ៥ | សេវាសង្គ្រោះបន្ទាន់សម្រាប់ករណីជំងឺធ្ងន់ធ្ងរក្នុងបន្ទប់សង្គ្រោះបន្ទាន់ | ២៥០ ០០០ | ២៥០ ០០០ | ៣០០ ០០០ | ៣២០ ០០០ |
| ៦ | វះកាត់តូច | ១៦០ ០០០ | ២០០ ០០០ | ៤០០ ០០០ | ៤០០ ០០០ |
| | គឺជាវិធីសាស្ត្រនៃការវះកាត់ (សល្យសាស្ត្រ) សម្រាប់បញ្ហា | | | | |

| | | | | | |
|---|---|---|---|---|---|
| | សុខភាព ឬ របួសហើយដែលត្រូវបានចាត់ទុកថា មិនគិតរាមកំហែង ឬ មានគ្រោះថ្នាក់ដល់អាយុជីវិតអ្នកជំងឺ ឬ ជនរងគ្រោះ។ តាមបទដ្ឋានវេជ្ជសាស្ត្រ គឺការវះកាត់ទាំងឡាយណាដែល÷<br>- ចំណាយពេលមិនលើសពី ១ ម៉ោង ដោយប្រើប្រាស់ថ្នាំស្ពឹក/សណ្តំ នៅនឹងកន្លែង ឬ មុខដែលត្រូវវះកាត់ (local anaesthesia) ហើយមិនស្ថិតនៅក្រោមកាលៈទេសៈណាមួយដែលនាំឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិត ឬ ដល់មុខងារនៃសរីរាង្គ ឬ ផ្នែកណាមួយនៃសារពាង្គកាយ។<br>ជាទូទៅការវះកាត់កម្រិតតូចមិនតម្រូវឱ្យនៅសម្រាកព្យាបាលទេ ហើយអាចធ្វើឡើងតាមរយៈការដាក់កម្មវិធីវះកាត់ដោយគ្រូពេទ្យវះកាត់ទូទៅ ចាប់ពីមន្ទីរពេទ្យបង្អែកកម្រិត ២ ឡើងទៅ។ | | | | |
| ៧ | វះកាត់ធំ | × | ៣២០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ |
| | ដំណើរការវះកាត់តឹងតែង និងពិបាក ដោយសារអាចប៉ះពាល់ដល់អាយុជីវិតអ្នកជំងឺ ឬជនរងគ្រោះ និងប្រើប្រាស់ពេលវេលាវែងលើសពីមួយម៉ោង។ ជាទូទៅ | | | | |

| | | | | | |
|---|---|---|---|---|---|
| | តម្រូវឱ្យប្រើប្រាស់ថ្នាំសណ្តំទូទៅ ហើយត្រូវនៅសម្រាកពេទ្យដែលមានរយៈពេល ជារៀយៗមួយសប្តាហ៍។ ការវះកាត់ ត្រូវធ្វើឡើងដោយគ្រូពេទ្យវះកាត់ទូទៅ ឬ គ្រូពេទ្យវះកាត់ឯកទេស។ ការវះកាត់ធំសំដៅដល់រាល់អន្តរាគមន៍/វះកាត់ទាំងឡាយនៅក្រោមលក្ខខណ្ឌចាំបាច់ដូចខាងក្រោមនេះ÷<br>- ប្រើប្រាស់ថ្នាំសណ្តំទូទៅ<br>- វះកាត់បើកចូលទៅក្នុងផ្នែកណាមួយនៃសារពាង្គកាយ<br>- អំឡុងពេលនៃអន្តរាគមន៍/វះកាត់ អាចជួបគ្រោះថ្នាក់/ហានិភ័យនៃការហូរឈាមច្រើន<br>- គ្រប់កាលៈទេសៈជីវិតរបស់អ្នកជំងឺស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់ ដែលអាចបាត់បង់ជីវិត។ | | | | |
| ៨ | សម្រាលកូន រំលូត/រលូត/ថែទាំក្រោយរំលូត/រលូត | ៨០ ០០០ | ៨០ ០០០ | ៨០ ០០០ | ៨០ ០០០ |

**ប្រការ៦.-**

មូលនិធិសមធម៌សុខាភិបាល អាចទូទាត់សេវាបញ្ជូនអ្នកជំងឺដែលជាប្រជាពលរដ្ឋក្រីក្រ ដល់មូលដ្ឋានសុខាភិបាលសាធារណៈ សម្រាប់តែករណីបញ្ជូនទាំងឡាយដែលត្រូវបានអនុវត្តតាមប្រព័ន្ធសេវាបញ្ជូនអ្នកជំងឺរបស់មូលដ្ឋានសុខាភិបាលសាធារណៈ។ សោហ៊ុយសេវាបញ្ជូន ត្រូវកំណត់ដូចខាងក្រោម÷

- ២០ ០០០ រៀល (ម្ភៃពាន់រៀល) ដល់ស្ត្រីមានផ្ទៃពោះម្នាក់ សម្រាប់ការធ្វើដំណើរមកសម្រាលកូននៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក ក្នុងចំងាយផ្លូវតិចជាង ឬ ស្មើ ១០ គីឡូម៉ែត្រពីផ្ទះ ឬ កន្លែងស្នាក់នៅ

- ២០ ០០០ រៀល (ម្ភៃពាន់រៀល) ដល់អ្នកជំងឺម្នាក់ សម្រាប់ការធ្វើដំណើរមកសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែក ក្នុងចំងាយផ្លូវតិចជាង ឬ ស្មើ ១០គីឡូម៉ែត្រពីផ្ទះ ឬ កន្លែងស្នាក់នៅ
- ៤០ ០០០ រៀល (សែសិបពាន់រៀល) ដល់ស្ត្រីមានផ្ទៃពោះម្នាក់ សម្រាប់ការធ្វើដំណើរមកសម្រាលកូន នៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យបង្អែក ក្នុងចំងាយផ្លូវលើសពី ១០ គីឡូម៉ែត្រពីផ្ទះ ឬ កន្លែងស្នាក់នៅ
- ៤០ ០០០ រៀល (សែសិបពាន់រៀល) ដល់អ្នកជំងឺម្នាក់ សម្រាប់ការធ្វើដំណើរមកសម្រាកព្យាបាលនៅមន្ទីរពេទ្យបង្អែក ក្នុងចំងាយផ្លូវលើសពី ១០គីឡូម៉ែត្រពីផ្ទះ ឬ កន្លែងស្នាក់នៅ
- ១០០ ០០០ រៀល (មួយរយពាន់រៀល) ដល់អ្នកជំងឺម្នាក់ សម្រាប់ការធ្វើដំណើរក្នុងករណីមន្ទីរពេទ្យបង្អែកបញ្ជូនបន្តទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យជាតិ/មជ្ឈមណ្ឌលជាតិ។

មូលដ្ឋានសុខាភិបាលសាធារណៈ អាចបើកប្រាក់ជាសោហ៊ុយសេវាបញ្ជូនដល់អ្នកជំងឺជាប្រជាពលរដ្ឋក្រីក្រដោយផ្ទាល់ ដើម្បីចាត់ចែងការធ្វើដំណើរ ក្នុងករណីដែលមូលដ្ឋានសុខាភិបាលសាធារណៈ មិនអាចចាត់ចែងសេវាបញ្ជូនខាងលើនោះបាន។

## ផ្នែកទី២

## កញ្ចប់ឧបត្ថម្ភសាច់ប្រាក់សម្រាប់ប្រជាពលរដ្ឋក្រីក្រ

### ប្រការ៧.-

អ្នកជំងឺជាប្រជាពលរដ្ឋក្រីក្រ ដែលមកប្រើប្រាស់សេវាសុខាភិបាល ស្របតាមប្រព័ន្ធសុខាភិបាលសាធារណៈត្រូវទទួលបានប្រាក់ឧបត្ថម្ភបន្ថែម ដូចខាងក្រោម÷

- ៥ ០០០ រៀល (ប្រាំពាន់រៀល) ក្នុង១ថ្ងៃ ដល់អ្នកជំងឺម្នាក់ដែលសម្រាកព្យាបាល សម្រាប់អាហារផ្សេងៗ។
- ៦០ ០០០ រៀល (ហុកសិបពាន់រៀល) ឧបត្ថម្ភបុណ្យសពសម្រាប់អ្នកជំងឺម្នាក់ស្លាប់ក្នុងមន្ទីរពេទ្យ និង/ឬ មណ្ឌលសុខភាព ។

មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវទទួលខុសត្រូវក្នុងការបើកប្រាក់ឧបត្ថម្ភបន្ថែមជូនអ្នកជំងឺជាប្រជាពលរដ្ឋក្រីក្រ ដោយផ្ទាល់ស្របតាមមុខសញ្ញាចំណាយខាងលើ។

## ផ្នែកទី៣

## ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់ កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

### ប្រការ៨.-

កម្មករនិយោជិតជាស្ត្រីទាំងក្នុង និងក្រៅប្រព័ន្ធ នៅពេលដែលសម្រាលកូន ត្រូវទទួលបានប្រាក់ឧបត្ថម្ភបន្ថែម ដូចខាងក្រោម÷

ក. សម្រាប់កូនទោល (មួយ) ទទួលបាន ៤០០ ០០០ រៀល (បួនរយពាន់រៀល) ។

ខ. សម្រាប់កូនភ្លោះ (ពីរ) ទទួលបាន ៨០០ ០០០ រៀល (ប្រាំបីរយពាន់រៀល) ។

គ. សម្រាប់កូនភ្លោះ (បី) ទទួលបាន ១ ២០០ ០០០ រៀល (មួយលានពីររយពាន់រៀល) ។

## ជំពូកទី៣
## ការគ្រោងថវិកា

**ប្រការ ៩.-**

ថវិកាកញ្ចប់សេវាព្យាបាលរបស់មូលនិធិសមធមិសុខាភិបាល ត្រូវគ្រោងក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល ដូចខាងក្រោម÷

- សម្រាប់ប្រជាពលរដ្ឋក្រីក្រ÷ ត្រូវគ្រោងក្នុងអនុគណនីលេខ ៦២០២១ (ជំនួយដល់ប្រជាជនសម្រាកពេទ្យ និងចំណាយដំណើរការរបស់មណ្ឌលថែទាំសុខភាព)។
- សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល និងប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន÷ ត្រូវគ្រោងក្នុងអនុគណនីលេខ ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត) ។

## ជំពូកទី៤
## នីតិវិធីអនុវត្តចំណាយ
### ផ្នែកទី១
### នីតិវិធីអនុវត្តចំណាយថវិកាមូលនិធិសមធមិសុខាភិបាល

**ប្រការ១០.-**

ថវិកាដែលបានមកពីការបង់ថ្លៃសេវាជូសអ្នកជំងឺនៅមន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព/ប៉ុស្តិ៍សុខភាព ក្នុងក្របខ័ណ្ឌមូលនិធិសមធមិសុខាភិបាល ត្រូវបានកំណត់បែងចែកប្រើប្រាស់ដូចខាងក្រោម ÷

- ៦០% សម្រាប់ការលើកទឹកចិត្តដល់មន្ត្រីសុខាភិបាលនៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ
- ៤០% សម្រាប់ចំណាយទ្រទ្រង់ដល់ដំណើរការរបស់មូលដ្ឋានសុខាភិបាលសាធារណៈ ដើម្បីពង្រឹងគុណភាពសេវាសុខាភិបាល ។

**ប្រការ១១.-**

យន្តការនៃការកំណត់អត្តសញ្ញាណអ្នកជំងឺក្រីក្រមុន (Pre-Identification) ជាការទទួលខុសត្រូវរបស់ក្រសួងផែនការ។ ក្រសួងផែនការធ្វើបច្ចុប្បន្នភាពស្ថានភាពក្រីក្ររបស់ប្រជាជន ជារៀងរាល់បីឆ្នាំម្តង, រួមទាំងការកំណត់អត្តសញ្ញាណអ្នកជំងឺក្រីក្រមុន និងការកំណត់អត្តសញ្ញាណអ្នកជំងឺក្រីក្រនៅមូលដ្ឋានសុខាភិបាល។

យន្តការនៃការកំណត់អត្តសញ្ញាណអ្នកជំងឺក្រីក្រនៅមូលដ្ឋានសុខាភិបាល (Post IDPoor) ជាការទទួលខុសត្រូវរបស់ក្រសួងសុខាភិបាល។ លក្ខណៈវិនិច្ឆ័យនៃការកំណត់អត្តសញ្ញាណអ្នកជំងឺក្រីក្រនៅមូលដ្ឋានសុខាភិបាល នឹងភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ។

**ប.ស.ស.** ត្រូវចេញបណ្ណមូលនិធិសមធម៌សុខាភិបាលដល់កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ១២.-**

មូលដ្ឋានសុខាភិបាលសាធារណៈត្រូវដាក់សំណើសុំការទូទាត់ថ្លៃសេវាសុខាភិបាល ដែលប្រើប្រាស់ដោយអ្នកជំងឺក្រីក្រ កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាលទៅ **ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល** ដើម្បីពិនិត្យផ្ទៀងផ្ទាត់បញ្ជាក់អំពីភាពត្រឹមត្រូវនៃសំណើ និងចេញវិក្កយបត្រស្នើសុំទូទាត់។

ក្រោយពីទទួលបានវិក្កយបត្រស្នើសុំទូទាត់ពីទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល ក្រសួងសុខាភិបាលត្រូវបើកផ្តល់សាច់ប្រាក់ដោយផ្ទេរចូលគណនីរបស់មូលដ្ឋានសុខាភិបាលសាធារណៈ នៅធនាគារពាណិជ្ជតាមការសម្រេចរបស់ក្រសួងសុខាភិបាល។

មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវរក្សាទុកឯកសារ លិខិតយុត្តិការ និងសក្ខីបត្រចំណាយផ្សេងៗសម្រាប់ជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ១៣.-**

ក្រសួងសុខាភិបាល ត្រូវបើកគណនីចរន្តចំនួនពីរជាប្រាក់រៀល នៅធនាគារជាតិនៃកម្ពុជា ឬធនាគារពាណិជ្ជដៃគូ ដើម្បីដំណើរការអនុវត្តថវិកាមូលនិធិសមធម៌ ក្នុងនោះ ទី(១) គណនីថវិកាបដិភាគនៃគម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាលសម្រាប់មូលនិធិសមធម៌អ្នកជំងឺក្រីក្រ និងទី(២) គណនីថវិកានៃមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

មន្ទីរពេទ្យជាតិ មជ្ឈមណ្ឌលជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ត្រូវបើកគណនីចរន្តជាប្រាក់រៀល នៅធនាគារពាណិជ្ជតាមការកំណត់របស់ក្រសួងសុខាភិបាល សម្រាប់ប្រតិបត្តិការដក និង/ឬ ដាក់សាច់ប្រាក់ ដើម្បីដំណើរការអនុវត្តថវិកាមូលនិធិសមធម៌សុខាភិបាលសម្រាប់ កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

**ប្រការ១៤.-**

នៅដើមឆ្នាំថវិកា ក្រសួងសុខាភិបាល អាចស្នើសុំបុរេប្រទានថវិកាមិនលើសពី ២៥% នៃឥណទានថវិកាប្រចាំឆ្នាំ ដើម្បីដំណើរការមូលនិធិសមធម៌សុខាភិបាល។

ការបើកផ្តល់បន្ទាប់ ត្រូវអនុវត្តតាមនីតិវិធីបំពេញឡើងវិញប្រចាំខែ។ ផ្អែកលើមូលដ្ឋានចំណាយរបស់មូលដ្ឋានសុខាភិបាលសាធារណៈ ក្រសួងសុខាភិបាល ត្រូវស្នើសុំទូទាត់ដោយបោះអាណត្តិបើកប្រាក់ព្រមជាមួយការស្នើសុំថវិកាបំពេញឡើងវិញ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេចបំពេញសាច់ប្រាក់ក្នុងគណនីមូលនិធិសមធម៌សេវាសុខាភិបាល។

ការស្នើសុំទូទាត់អាចអនុវត្តច្រើនដងក្នុងមួយឆ្នាំតាមការជាក់ស្តែង ដើម្បីធានាថាក្រសួងសុខាភិបាលមានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់បើកផ្តល់ឱ្យមូលដ្ឋានសុខាភិបាល ។

**ប្រការ១៥.-**

ថវិកាមូលនិធិសមធម៌សេវាសុខាភិបាល សម្រាប់ប្រជាពលរដ្ឋក្រីក្រ ត្រូវអនុវត្តតាមនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង ដោយអនុលោមតាមអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍។

**ប្រការ១៦.-**

ក្រសួងសុខាភិបាល ត្រូវធ្វើរបាយការណ៍បិទបញ្ជីចំណូល-ចំណាយប្រចាំឆ្នាំ ស្របតាមបទដ្ឋានគតិយុត្តហិរញ្ញវត្ថុជាធរមាន។

អនុញ្ញាតឱ្យក្រសួងសុខាភិបាល រក្សាសមតុល្យសាច់ប្រាក់ចុងឆ្នាំសារពើពន្ធ ក្នុងគណនីថវិកាបដិភាគនៃគម្រោងលើកកម្ពស់គុណភាពនិងសមធម៌សុខាភិបាលសម្រាប់មូលនិធិសមធម៌អ្នកជំងឺក្រីក្រ និងក្នុងគណនីថវិកា នៃមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ កីឡាករ កីឡាការិនី ក្រុមប្រឹក្សាឃុំ-សង្កាត់ មន្ត្រីភូមិ និងក្រុមគោលដៅអាទិភាពផ្សេងៗទៀតតាមការសម្រេចរបស់រាជរដ្ឋាភិបាល ដោយចាត់ទុកជាថវិកាបុរេប្រទានសម្រាប់អនុវត្តឆ្នាំបន្ទាប់ និងត្រូវអនុវត្តនីតិវិធីបំពេញឡើងវិញនៅពេលដែលឥណទានថវិកាឆ្នាំថ្មីត្រូវបានដំណើរការ។

## ផ្នែកទី២
## នីតិវិធីអនុវត្តចំណាយ
## ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន

**ប្រការ១៧.-**

**បេឡាជាតិរបបសន្តិសុខសង្គម** (ប.ស.ស.) ត្រូវទទួលខុសត្រូវបើកផ្តល់ដោយផ្ទាល់ នូវប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូនទោះបីជាទារករស់ ឬក៏ស្លាប់ក៏ដោយ។

**ប្រការ១៨.-**

នៅដើមឆ្នាំថវិកា ក្រសួងសុខាភិបាល អាចស្នើសុំបុរេប្រទានថវិកាមិនលើសពី ២៥%នៃឥណទានថវិកាប្រចាំឆ្នាំនៃប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីសម្រាលកូន ដើម្បីបើកផ្តល់ជូន **ប.ស.ស.**។

ការបើកផ្តល់បន្ទាប់ ត្រូវអនុវត្តតាមនីតិវិធីបំពេញឡើងវិញ ដោយ **ប.ស.ស.** ត្រូវរៀបចំឯកសារស្នើសុំទូទាត់មកក្រសួងសុខាភិបាល និងស្នើសុំបំពេញឡើងវិញ តាមចំនួនថវិកាដែលបានបើកផ្តល់ជាក់ស្តែង។ ការស្នើសុំទូទាត់អាចអនុវត្តច្រើនដងក្នុងមួយឆ្នាំតាមការចាំបាច់ ឬ តាមខែ ដើម្បីធានាថា **ប.ស.ស.** មានសាច់ប្រាក់គ្រប់គ្រាន់សម្រាប់បើកប្រាក់ឧបត្ថម្ភបន្ថែមដល់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន។

ផ្អែកលើមូលដ្ឋានសំណើរបស់ **ប.ស.ស.** ក្រសួងសុខាភិបាលត្រូវបោះអាណត្តិទូទាត់ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច និងបើកផ្តល់សាច់ប្រាក់ជូន **ប.ស.ស.**។

ក្រោយពីទទួលបានអាណត្តិបើកប្រាក់ អគ្គនាយកដ្ឋានរតនាគារជាតិត្រូវបង្វែរសាច់ប្រាក់ចូលគណនីផ្ទាល់របស់ **ប.ស.ស.** នៅរតនាគារជាតិ។

**ប្រការ១៩.-**

**ប.ស.ស.** ត្រូវធ្វើរបាយការណ៍បិទបញ្ជីចំណូល-ចំណាយប្រចាំឆ្នាំ ស្របតាមបទដ្ឋានគតិយុត្តហិរញ្ញវត្ថុជាធរមាន។

អនុញ្ញាតឱ្យ **ប.ស.ស.** រក្សាសមតុល្យសាច់ប្រាក់នៅចុងឆ្នាំសារពើពន្ធ ដោយចាត់ទុកជាថវិកាបុរេប្រទានសម្រាប់ឆ្នាំបន្ទាប់ ដើម្បីបន្តបើកប្រាក់ឧបត្ថម្ភដល់កម្មករនិយោជិតជាស្ត្រីសម្រាលកូន និងត្រូវអនុវត្តនីតិវិធីបំពេញឡើងវិញ នៅពេលដែលឥណទានថវិកាឆ្នាំថ្មីត្រូវបានដំណើរការ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**ប្រការ២០.-**

ប្រកាសអន្តរក្រសួងលេខ ៨០៩ សរចប ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ឧបត្ថម្ភអ្នកជំងឺក្រីក្រ និងប្រការ ៨ នៃប្រកាសអន្តរក្រសួងលេខ ៤០៤ កប/ប្រកបសស ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៧

ស្តីពីការអនុវត្តការថែទាំសុខភាព តាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធនិងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន ត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ២១.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវបានចាត់ទុកជានិរាករណ៍ ។

**ប្រការ២២.–**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន បេឡាជាតិរបបសន្តិសុខសង្គម ទីភ្នាក់ងារបញ្ជាក់ចំណាយសេវាសុខាភិបាល និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ព.ស. ២៥៦[illegible]

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ[illegible] ឆ្នាំ២០១៨

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

រដ្ឋមន្ត្រី
ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

អ៊ិត សំហេង

រដ្ឋមន្ត្រី
ក្រសួងសុខាភិបាល

ម៉ម ប៊ុនហេង

កន្លែងទទួល÷

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ២២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : [illegible]

ថ្ងៃ អង្គារ ១៣រោច ខែ ផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ២០១៨

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្រកាសបង្កើតសាខារោងចក្រកាត់ដេរសម្លៀកបំពាក់ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រុមហ៊ុន យូ អាយ ស៊ី អឹកែរឹល មេនូហ្វេកធឺរីង

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន យូ អាយ ស៊ី អឹកែរឹល មេនូហ្វេកធឺរីង (U.I.C APPAREL MANUFACTURING CO., LTD.) តំណាងដោយ លោកស្រី **PAN, MEI-TZU** បង្កើតសាខារោងចក្រ កាត់ដេរសម្លៀកបំពាក់ ដែលមានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ ភូមិវល្លិសរ ឃុំវល្លិសរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ . ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 Fax: 855-23-428263

| **ឈ្មោះផលិតផល** | **លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code |
|---|---|
| សម្លៀកបំពាក់ | ១៤១០ |

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះ រោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** "រោងចក្រកាត់ដេរសម្លៀកបំពាក់ យូ អាយ ស៊ី អ៊ីតែរីល មេនូហ្វេកធឺរីង (សាខាទី១)"

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួង ឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។ ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានទាន់ពេលវេលាអំពីករណីប្រែប្រួល ហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាម មាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១១៖** ម្ចាស់រោងចក្រ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម រយៈពេល ០១ខែយ៉ាងតិច មុនថ្ងៃដែលខ្លួនបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ។ ករណី រោងចក្រផ្អាកដំណើរការជាប់ៗគ្នា ក្នុងរយៈពេល១២ខែ ឬមិនបានផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែជាប់ៗគ្នារយៈពេល ០៣ខែ ត្រូវចាត់ទុកថា ជាការបញ្ឈប់ដំណើរការរោងចក្រជាស្ថាពរ ស្របតាមមាត្រា១៥ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១២៖** លក្ខខណ្ឌនានារបស់ប្រកាសនេះ អាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា៣៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង តាមលក្ខខណ្ឌទាំងឡាយនៃប្រកាសនេះ។

**ប្រការ១៣៖** ម្ចាស់រោងចក្រ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងលិខិតបទដ្ឋានគតិយុត្តិនានាពាក់ព័ន្ធនឹងវិស័យឧស្សាហកម្ម។ ក្នុងករណីល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១៤** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះ តាមមុខការ រៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**ហេង សុខគង់**

**ចម្លងជូន៖**
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងបរិស្ថាន
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-សាលាខេត្តកំពង់ស្ពឺ
-មន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពង់ស្ពឺ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី